ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS ET COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

នាយកាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ណារក្ស
ពុទ្ធសាសនបណ្ឌិត្យ

នាយកាធិការ ផ្នែកជំណឹងសាសនា: ព្រះគ្រូសុវណ្ណញាណ ស្វា-ហ៊ុយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| លោក ហ្វ្រង់ស្វ ម៉ារទីនី ទីប្រឹក្សា ក្រសួងធម្មការ | ពាក្យពន្យល់សេចក្តីផ្សេងៗ ក្នុងរឿងរាមកេរ្តិ៍ | |
| | ប្រណាខ្មែរ | ៣២១ |
| លោក ភិយ-ប៊ុក សមុហបញ្ជីធំ | សេចក្តីកត់សំគាល់របស់អ្នកប្រែ | ៣២៦ |
| អ្នកឧកញ៉ាវិបុលរាជសេនា (នូ-កន) | រឿងសាមកុក (តមក) | ៣២៨ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ប្រវត្តិសាស្ត្រសង្ខេបប្រទេសចិន (តទៅ) | ៣៣៤ |
| លោក ភិយ-ប៊ុក សមុហបញ្ជីធំ | រឿង ស៊ុន-យ៉ាត់-សេន (តមក-ចប់) | ៣៤៥ |
| **ផ្នែកសាសនា** | | |
| ព្រះសង្ឃព្រះវិភទ្ទញាណ សាម-ឡុច ក្រុមជំនុំព្រះត្រៃបិដក | មធុរភាសិត | ៣៦៣ |
| ព្រះគ្រូពោធិវង្សាចារិយាព្រៃទ្ធ ធន-កំង | ពិធីទក្ខិណានុប្បទានទិនកម្មវិធីព្រះសពសម្តេច | ៣៦៨ |
| ឃុនសិរិមេធី ស្រី-អ៊ូ | ប្រវត្តិនិងពិធីបូជាព្រះសព សោម-ឡុច | ៣៧៧ |
| ព្រះវិន័យធម្ម យូរ-ប៊ុណ្ណ | បក្កធម្ម | ៣៨៨ |

ឆ្នាំទី ២១ — លេខ ៥ ខែ ឧសភា ឆ្នាំ ១៩៤៩ — ដំឡៃជាវ ១ ឆ្នាំ ៦៨ រៀល

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantri Nhok-Thêm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah grū Suvaddhannāna So-Hay membre de la Commission du Tripitaka

## TABLE DES MATIÈRES

### Partie littéraire :

| | | page |
|---|---|---|
| Monsieur François Martini Conseiller aux cultes | En marge du Rāmāyana Cambodgien. | 321 |
| Monsieur Ray - Buc Chef Comptable (I.B.) | Note du Traducteur .............. | 326 |
| Oknha Vipularājssenā Nou-Kan Député | Histoire de Sam kok (suite)...... | 328 |
| Luong Nibandhamantri Nhok-Thêm | Histoire de Chine (suite) .......... | 339 |
| Monsieur Ray - Buc Chef Comptable (I. B.) | Un épisode de la vie de Sun-Yat-Sen, homme politique chinois ( suite et fin ) .................. | 345 |

### Partie religieuse:

| | | |
|---|---|---|
| Vén. Som - Loch ancien membre de la commission du Tripitaka | Madhuraphasit.................. | 353 |
| Vén. Brah grū Bodhivannsa Reach-Kœung professeur à l'E.S.P. | Cérémonie d'incinération de S. E. le Samdach Brah Mahā Sumédhathipati Prak-Hin (suite et fin)...... | 368 |
| Khun Sirimédhi Srey-Ou membre de la commission du Tripitaka | Biographie et cérémonie d'incinération du Vén. Brah Viphaddannana Som-Loch ................... | 377 |
| Vén. Brah Vinayadhamma You-Ponn membre de la commission du Tripitaka | Cakkadhamma .................. | 388 |

## ពាក្យពន្យល់

## សេចក្ដីផ្សេងគ្នាក្នុងរឿងរាមាយណៈខ្មែរ

ក្នុងបឋមបរិយាយអំពីរឿងរាមាយណៈ ដែលបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីរបស់សាលាបារាំងសែស ចុងបូព៌ាប្រទេស(១) ដែលខ្ញុំបានរំលឹកអំពីផលប្រយោជន៍ នៃការពិនិត្យមើលរឿងរាមាយណៈ ដែលមានសេចក្ដីប្រែជាភាសាខ្មែរ គឺរឿង "រាមកេរ្តិ៍" ដើម្បីជាការបញ្ជាក់ឲ្យដាច់ខាត អំពីក្បាច់ចម្លាក់ខ្លះនៅប្រាសាទអង្គរវត្ត ។ បើប្រសិនជាមានរឿងក៏ក្នុងស្រុកដំណាលពីរឿងព្រេង ព្រោះរាមកេរ្តិ៍នេះ ប្រហែលជាពួកវិចិត្រសិល្បករទំនើបខ្មាប់ (ជាជនម្នាក់) ខ្មែរ គង់មានគំនិតស្រូបយកពីករណីយហេតុ ដែលខ្លួនគ្រាន់បានចាំយករចនាមិនបាន ។

យើងបានឃើញដំណើរថ្លែងសរជ័យ មានសេចក្ដីផ្សេងគ្នាពីរយ៉ាង គឺៈ ១ ក្នុងភាសាសំស្ក្រឹតបរិយាយពីរបុរស បានដាច់បំបាក់ធ្នូសរជ័យ ក្នុងការល្បងមើល ។ ១ ក្នុងភាសាខ្មែរ សរជ័យទុកពេលទីងកន្លែង បញ្ជាក់ឲ្យឃើញថា អ្នកដំឡើងសរជ័យមិនប្រសប់រកគ្រូរៀបជួយគ្នា ឯជាងចម្លាក់ខ្មែរចូលចិត្តនាំយករឿងព្រេងនេះមករចនា ដូចមានសេចក្ដីដំណាលជាភាសាខ្មែរស្រាប់ ។

---

១ ភាគទី ៣៨ ខ្សែ ២ ទំព័រ ២៧៥ ។

មានឧទាហរណ៍ ១ ទៀត គេបានដកស្រង់យកពីសេចក្ដីប្រកាស ទំនៀមស្រុក និយាយត្រង់រឿងយក្សឈ្មោះវិរាធៈ ចាប់ឆក់យកនាង សីតាទៅ ។ ឯការពិពណ៌នារឿងនោះ គេឃើញឆ្លាក់ជាក្បាច់ផ្ទាំង លេខ B.219 នៅថែវជ្រុងទិសពាយ័ព្យ លោកហ្សកសេដេស អធិប្បាយបញ្ជាក់រឿងនេះ ដូចមានសេចក្ដីតទៅនេះ ៖

"មានចម្លាក់លំអជាដងព្រៃមួយ យក្ស ១ ពរស្ត្រីម្នាក់ដោយដៃ ខ្លួនហើយគេក្រោកការពារនាងដោយគ្រលំទំនួកថ្វីសរពីរនាក់ ដែល ស្រួលស្គាល់លក្ខណៈមុនថាជាគូព្រះរាមនិងព្រះលក្ស្មណ៍ ។ យើងបាន ឃើញថា រឿងដូច្នេះ មានដំណាលតែក្នុងរឿងរាមាយណៈ ។

កាលមុនពីកាលដែលរាពណ៍ចាប់យកនាងសីតាទៅ ព្រះរាម ព្រះលក្ស្មណ៍មិនដែលមានការគោរពក្រោមនាងសីតាទេ ហើយរឿងនេះមិន មែនជាបញ្ហាកន្លែងនេះផង មានតែរឿងមួយ កាលព្រះរាម ព្រះលក្ស្មណ៍ ពីរនាក់បងប្អូនការពារនាងសីតា ពីទីនក្មេងឈ្មោះវិរាធៈតែម្ដង ដែល យក្សនេះចង់ឆក់យកនាងសីតាទៅដើម្បីធ្វើការគំជាអាហារ ហើយ កំពើពិឃាតអ្នកការពារទាំងពីរនាក់ ។ ក៏ស្រាប់តែលោកទាំងពីរ ស៊ីយក្ស ហើយបានកាត់ដៃយក្សម្នាក់ ៗ តាមដោយពិតនោះ ឰក្រណ៍ឆ្លាក់ មិនបានឆ្លាក់តាមរឿងដែលមានពិតៗនោះទេ ហើយគេបាន ឆ្លាក់ជារូបសះជ័យរបស់បងប្អូនពីរនាក់ ជំនួសរូបព្រះខំនវិញ ។

ប៉ុន្តែមិនគួរយល់ថា រឿងដែលមានទំនងខុសគ្នាបន្តិចបន្តួចនេះ មិនអាចកែប្រែសេចក្តីបរិយាយដែលបានអធិប្បាយមកខាងលើនេះទេ" ។

ខ្ញុំបានធ្វើសញ្ញាប្រកាស ក្រោយប្រយោគដែលខ្ញុំសង្ស័យ ថាគួរជាផ្លាក់ផ្លោះបន្ទាត់ខាងទំនើងចិត្តដល់ខ្លួន ពីព្រោះជាងបម្រាក់នៅតែងផ្លាក់តាមរឿងដែលមានពិត ៗ ប៉ុន្តែគេបានចិត្តឃើញទៅដល់រឿងផ្សេង ៗ ដែលគេបានបន្ទាន់ឡើងតាមគំនិតថ្មី ហើយទៅជារឿងបន្ថែមពីរនាក់នយុទ្ធទឹងពាក្យដោយប្រើសំដែងជាកាព្យ មិនប្រើព្រះវចនៈ ។ តាមដោយពិតការពេយុទ្ធទំនងនេះ ដូចខាងបរិយាយ អាងរឿងកម្រង្គរទៅនេះ

ពិតផលពាក្យកាព[១] គួលធគសិរ ទេពីព្រះបាទនរបតី ។ រៀងតហ៍, យ, ម, តាល់ទី គារឯងឥតបី នានិងថ្ងៃថ្មីទឹកបមា ។ ជងនោះព្រះនាគយណ៍ពាមា ទ្រង់ព្រះក្រោធា បំដួចអ្នកផុតនៃអគ្គី ។ ស្រេចស្តេចដាក់ព្រតពិធី ហើយព្រះចក្រ ក៏ទ្រង់កៅទណ្ឌសាថ្វា ។ ក្សណនោះព្រះលក្សណ៍អនុជា ទូលព្រះជេដ្ឋា- ធិរាជសូមសុំព្រះពរ ។ ខ្ញុំសូមគាសារយោគវ ដាយបុថ្ងៃយប- រមនាថបពិត្រនេះឥឡូវ ។ ទូលៈស្រេចស្តេចទ្រង់ឃ្លុំឃុខទូស សារក្តីព្រះគូ- ធារទ្រូធិបជនោះក៏ទ្រង់ ។ គោះគាំ

១ "រាមកេរ្តិ៍" សៀវភៅបោះពុម្ពរបស់ព្រះរាជបណ្ណាល័យ ភ្នំពេញ ឆ្នាំ ១៩៣៧ ភាគ ៣ ទំព័រ ១-៣ ។ យើងបានទុករបៀបអក្ខរាវិរុទ្ធតាមអ្នកបោះពុម្ព ពិតមែនតែរបៀបនេះមិនត្រូវសមតាមច្បាប់ស្ទើកវិត ។

ផាញជ័យរឿណរង្គ យក្សាប័ទ្រខន់ ជំនាញជំនះមហិមា ។ តែចូល
ច្បាំងព្រះអនុជា ដួចគល់បញ្ចា ទាំងពីរប្រទះប្រតិពល ។ ព្រះកាយ
ព័ទ្ធរបោតបក់ផល- សារសោតដោមដល់ រលតរលុបពសុធា ។ ព្រះ
អនុជចូលយុទ្ធយក្សា យក្សសោកមហិមា ក្រតាក្រខួសតាស់ខែន ។
ស្ទុះកូលតាប់ព្រះស្តេចថ្លៃន សាកសំដែន សំញ្ញែនទួរគេជោជ័យ ។ ផន
នោះព្រះជមថ្ងៃក្រៃ យល់ព្រះអនុជខែ ប្រយុទ្ធនូវយក្សជាក់ដើរ ។
ទើបព្រះនានាថដ៏ប្រសើរ យល់ព្រះអនុជស្មើរ ក៏ថ្លៃនិសាកសរផ្លួល ។
ព្រះចូលតាប់យក្សាធ្លូរ យក្សយុទ្ធប្រែប្រួល បំណាន់នូវតាប់ព្រះចក្រ ។
យក្សក៏ផាន់ស្លួលជ័យស្រែ ចូលតាប់ព្រះចក្រ គ្រវីព្រះខ័នក់កាយ ។
យក្សនូវអនុជនាថនាកយណ៍ រំពួលពសុធាធ្លាយ កំទ្បាំងពន្លឹកយុទ្ធ
ក្រៃ ។ ស្តេចផច្បសិល្បសរដើរជ័យ ថ្លៃនផ្កាញក្បូណក្ស័យ ពិពាធ
កំដួលដំណាក ។ ធ្លាក់ព្រឹក្សព្រៃបែកបញ្ចា អស់ទេពគិរីគ្រា ស្មុគរីជ័យ
ថ្វាយតារ ។ ស្តេចផ្គួលពិពាធលុះដល់មរណ៍ ដោយតេជៈឥរ ស្រេច
ជុតអស្សុរប្រាថ៍[១] ។

---

១ តាមសេចក្តីខាងក្រោយនេះ មានប្លែកពីគ្នាខ្លះដែរ គឺក្នុងរឿងរាមាយណៈរបស់ វាល្មីកិ ថាបងប្អូនពីរនាក់ ក្រោយដែលបានពិឃាតយក្សវិរាធហើយ បានយកព្រះខ័នកាត់ ដៃយក្ស ហើយបានយកយក្សនោះទៅកប់នៅក្នុងរណ្តៅមួយពីព្រោះមានវិទ្ធិមន្តអាគម ១ ការកាយក្សក្សែសមិនឲ្យភ្ជាប់ដោយភាពផ្សេងពីនេះ ។

ដូចគេបានឃើញស្រាប់ ប្រសិនបើជាងម្នាក់ក្បាច់ផ្ញាំងនៅអង្គរវត្ត បានឆ្លាក់ជារូបសដោយជំនួសព្រះវិនរបស់បង្អួចពីរនោកនោះ ផ្ទៃហេតុតួជាឯផល់នោះបានឆ្លាក់ទៅតាមរឿងទំនៀមទម្លាប់ស្រុក ដែលមានដំណើររឿងវែងតាមរឿងរបស់កល្បិត ហើយមានស្ថានភាពស្របគ្នាពេញរឿងដែលគេបានឆ្លាក់ទុកនៅប្រាសាទអង្គរវត្ត ទាំងសម័យដំណាលគុំរឿងរាមកេរ្តិ៍ នាំឲ្យសេចក្តីផ្សេងរឿងខាងក្រោយនេះ មានដំឡៃថ្លៃថ្នូរទុកជាគោលចារ៉ែយ៉ាងសំខាន់ ១ សម្រាប់វិជ្ជាខាងទំនៀមទម្លាប់ខ្មែរ ។

បើគេយកពាក្យពេចន៍នេះទៅប្រៀបធៀបឲ្យវែងឆ្ងាយទូលាយទៅទឹងក្បាច់ផ្ញាំងផ្សេងៗទៀតរបស់ខ្មែរ គាប់ជួយឲ្យអ្នកសិក្សាវិជ្ជាកាសា·សាស្ត្រ កំណត់ប្រមាណសម័យនៃការប្រែប្រៀងរឿងរាមកេរ្តិ៍នេះបានប្រាកដ ។

ហ្វ្រង់ស្វា . ម៉ារ៉េន

# សេចក្តីកត់សំគាល់របស់អ្នកប្រែ

គេដឹងថា ក្នុងចំណោមក្បាច់ផ្ចាំង ដែលគេឆ្លាក់លំអនៅផ្ចាំងប្រាសាទអង្គរវត្ត មានក្បាច់ផ្ចាំងច្រើនពណ៌នាពីរឿងរ៉ាវ ដែលជាស្រង់យកមកពីរឿងព្រេងព្រះរាម ។ ពួកបណ្ឌិតបារាំងសែសមានលោកហ្វីណូតនឹងលោកសុីដេសជាដើម បានពិនិត្យដោយពិស្តារនូវក្បាច់ផ្ចាំងទាំងនោះ ហើយបានឃើញយ៉ាងជាក់ច្បាស់ នូវរឿងរ៉ាវដែលឆ្លាក់ទៅលើទានៅទីនោះ ស្ទើរតែទាំងអស់ ។ ប៉ុន្តែលោកអ្នកប្រាជ្ញអស់នោះមានសេចក្តីឆ្ងល់ថា ក្បាច់ចំឡាក់ខ្លះដែលបានយល់ជាក់ច្បាស់ក្នុងចិត្ត ព្រោះអាស្រ័យរឿងរ៉ាវទាំងមូលតែគង់មានកន្លែងខ្លះខុសគ្នានឹងរឿងរាមាយណៈ បើតាមការពិចារណាដោយពិស្តារ លោកយល់ដោយដាច់ខាតថា ពួកជាងឆ្លាក់ខ្មែរ មិនបានឆ្លាក់ទៅតាមរឿងកវីនិពន្ធពិតៗទេ គេចូលចិត្តចង់រចនាសិល្បៈអស់នោះទៅតាមទំនើងចិត្តរបស់ខ្លួនវិញ ។ ហេតុដូច្នេះ បានជាលោកម៉ាទីន ទីប្រឹក្សាបច្ចុប្បន្ននៅក្រសួងធម្មការនិងសិល្បករបានបញ្ជាក់នូវបរិយាយដែលបានបោះពុម្ពផ្សាយ កាលពី១០ឆ្នាំមុននេះថា សភាពដ៏ខុសគ្នាដូច្នេះ ដែលនាំឲ្យពួកបណ្ឌិតគាំងបុកណារ់ក្នុងក្បាលងឿងឆ្ងល់នុ៎ះ មិនមែនមកពីទំនើងចិត្តរបស់ពួកវិចិត្រសិល្បករទេ ប៉ុន្តែមកពីពួកជាងចម្លាក់ខ្មែរ បានចេះចាំនូវរឿងរ៉ាវផ្សេងពីរឿងរាមាយណៈសំស្ក្រឹតនេះទៅទៀត ពួកអ្នកប្រាជ្ញ

ដែលមាននាមខាងលើនេះ  ប្រឹងនាំយកគោលមតអាងដោយប៉ុន្តប្រទៀ ទេ ។ លោកសាស្ត្រាចារ្យម៉ាទីន  បានបញ្ជាក់ថារឿងពីរដែលផ្សេងនោះ  គឺរឿងព្រេងព្រះរាម  ដែលបកប្រែជាភាសាខ្មែរ  ហៅថា រាមកេរ្តិ៍ ។ លោកសាស្ត្រាចារ្យនេះបានយករឿងរាមកេរ្តិ៍ខ្មែរនឹងរឿងរាមាយណៈសំស្ក្រឹតមកប្រៀបធៀបគ្នាមើល  ហើយបានយល់ឃើញថា បើទុកជារឿងព្រេងទាំងពីរនេះ មានអត្ថដូចគ្នា ចំណែកខាងកវីនិពន្ធខ្មែរ បើតាមពិនិត្យដោយពិស្តារ  ឃើញមានកន្លែងខ្លះខុសគ្នា  ហើយបានបញ្ចូលរឿងថ្មីទៀត  ដែលគ្មានក្នុងកវីនិពន្ធសំស្ក្រឹត ។ ហេតុនេះ ពួកជាងចំឡាក់សម័យអង្គរវត្ត បានឆ្លាក់ក្បាច់អស់នោះទៅតាមរឿងដែលបកប្រែជាភាសាខ្មែរ  ហៅថា  រាមកេរ្តិ៍ ។ ពួកវិចិត្រសិល្បករខ្មែរមិនមែនឆ្លាក់ក្បាច់អស់នោះ  ដោយទំនើងចិត្តរបស់ខ្លួនទេ  គឺធ្វើទៅតាមទំនៀមទម្លាប់ស្រុកសំដែងអំពីរឿងព្រេងព្រះរាម  ដែលមានអត្ថខុសគ្នានឹងសេចក្តីបកប្រែជាភាសាសំស្ក្រឹត ។

យើងមានពេញចិត្តក្នុងពេលបច្ចុប្បន្ននេះ  ដែលបានចុះផ្សាយសេចក្តីប្រែនៃបរិយាយថ្មី អំពីរឿងនេះ  ដែលលោកច័ប្រែក្យា  ម៉ាទីន ប្រែនឹងយកទៅចុះផ្សាយក្នុងទស្សនាវដ្តីបារាំងសែសជាប្រយោជន៍ដល់ការសិក្សាខាងបូព៌ាប្រទេស ។

ពាយ - ប៊ុត

# រឿងសាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូរ-កន ប្រែ

(តមក)

---

ឯហាន់ឃុនក៏លើកទាហានតែចេញទៅតាមទ្វារទិសខាងកើត ជូហ៊ី ឡៅពី កួនអ៊ូ តៀវហ៊ុយ ទាំង ៤ នាយក៏បរពលដេញតាមទៅបាន បាញ់ទឹងត្រូវហាន់ឃុនស្លាប់ ពួកទាហានចោរក៏រត់បែកខ្ចាត់ខ្ចាយទៅ ។

### វគ្គទី ២

ពាំងពីជូហ៊ី ឡៅពី កួនអ៊ូ តៀវហ៊ុយ ច្បាំងនឹងតៀវហាន់, ស៊ុនឃុង ពួកចោររត់ខ្ចាត់ខ្ចាយទៅ ផលតាំងគុង្វើបុគហ្មាចក្រាបបង្គំទូលព្រះចៅឡេនតេ សុំលើកទ័ពចូលទៅស្រុកឡុកអៀងជាទីក្រុង ដើម្បីនឹងចាប់ខ្លួនតៀវលៀង នឹងពួកទន្តី ៩ នាក់សម្លាប់ ។

ឯជូហ៊ី ឡៅពី កួនអ៊ូ តៀវហ៊ុយ ទាំង ៤ នាយ លើកពលតាមទៅជួបប្រទះនឹងតៀវហាន់ ស៊ុនឃុនដែលជាពួកហាន់ឃុននោះ តៀវហាន់ ស៊ុនឃុន ការទាហានកងទ័ពមុខតទល់នឹងទ័ពជូហ៊ីៗ ឃើញពលតៀវហាន់ច្រើនលើសលុបក្រែងទប់ពុំឈ្នះ ក៏ក្រឡាស់ថយទ័ពត្រឡប់មកវិញ តៀវហាន់ ស៊ុនឃុន ក៏ដេញសង្កៀញតាមទៅដណ្តើមយកស្រុកអួនសៀបានវិញ ជូហ៊ីក៏ថយទៅតាំងបន្ទាយឆ្ងាយពីស្រុកនោះប្រមាណមួយយោជន៍ (៤ គីឡូម៉ែត្រ) ជូហ៊ីគិតនឹងលើកពលចូលដណ្តើមយក

ស្រុកអ្នកសៀមទៀត ទទួលក្រឡេកទៅឃើញទាហាន ១ ពួកលើក មកតាមផ្លូវទិសខាងកើត ឯនាយទាហានដែលលើកមកនោះ ឈ្មោះ ស៊ិនកៀន គិរិយាដូចខ្លា ថ្ងាសទូលាយ មុខវែង កើតនៅស្រុកគងជី ។ ស៊ិនកៀននោះ កាលអាយុ ១៧ ឆ្នាំ បាននៅស្រុកបៀនតង់ជាមួយនឹង បិតា ទៅដល់មាត់ស្ទឹងស្រុកបៀនតង ប្រទះនឹងពួកចោរ ១០ នាក់ វាប្លន់ ដណ្ដើមយកទំនិញ ហើយរត់ផ្ញាន់ទៅតរលើគោក ស៊ិនកៀនខឹង ណាស់និយាយនឹងបិតាថា ចោរទាំងអស់នេះអាក្រក់ខ្លាំងណាស់ ខ្ញុំនឹង ឡើងទៅចាប់ខ្លួនវាឲ្យបាន ហើយស៊ិនកៀនក៏ដើរឡើងទៅធ្វើកាការប៉ីដូច នាហ្មឺនស្រុកហៅបារព្រាវទាំងពួងអឹងគង ឯចោរ ១០ នាក់ឃើញក៏កក់ ក៏យកតែចោលរបស់ទ្រព្យអស់ ស៊ិនកៀនដេញតាមសម្លាប់ចោរបានម្នាក់ ៩ នាក់រត់រួចទៅ. កិត្តិស័ព្ទទាំងនេះ ក៏ល្បីលេចឮទៅដល់ចៅហ្វាយ ស្រុកបៀនតង់ៗឲ្យហៅយកខ្លួនស៊ិនកៀនទៅ តាំងឲ្យធ្វើជានាយទាហាន អំណើះតមក ហ៊ឹកុតជាមនុស្សក្បត់ឃុំនាំពលបានប្រែនម៉ឺនតាំងខ្លួនជា ស្ដេចឈ្មោះឃុំងបេង នោះអ្នកក្រុងស្រុកនឹងស៊ិនកៀនជីងជំណាំង ក៏ បញ្ជូរបញ្ចូលពលទាហានកុងស្រុកដែលខ្លាំងពូកែបានមួយពាន់ប្លាយ លើកទៅច្បាំងឯស្រុកហ៊ឹកុងកាប់ហ៊ឹកុងនឹងកូនហ៊ឹកុងស្លាប់ អ្នកក្រុងស្រុក ក៏បកសំបុត្រចូលទៅក្រាបបង្គំទូលព្រះចៅឡេនតេ សូមព្រះរាជទាន សេចក្ដីតាប់ប្រសើរឲ្យស៊ិនកៀន លុះកើតពួកចោរជួតក្បាលលឿង លើក

ពួកពលកងក្បាលកាប់សំឡាប់អ្នកស្រុកតែប៉ុន្តែតណ្ហាកាន់តែកំរើបខ្លាំងឡើង ស៊ិនកៀនជំនិះជំណាំងថា ដូច្នេះកំពុងបង្ក្រាបពួកចោរក៏មានសេចក្តីត្រេកអរណាស់ ក៏តាំងបញ្ចុះបញ្ចូលពួកអ្នកស្រុកហើយនិងទាហានស្រុកអន្ទសៀមទាំង ២ តំបន់នេះ បានពលប្រមាណមួយពាន់ប្រាំរយ ក៏លើកបណ្តាយមកស្រុកអន្ទសៀម៖ កាលមកដល់ទល់នឹងកំពង់ដូហ៊ាហើយក៏ចូលទៅជួបនឹងដូហ៊ាថា ខ្ញុំបាទបបួលមកសូមយកគាសាកម្ចាត់ពួកចោរ ៗ ដូហ៊ាមានសេចក្តីត្រេកអរណាស់ ទើបតាំងកាត់ថែនទាហានប្រគល់ឲ្យទៀតពីរលើកទៅកាប់ចោះខ្ទាះ តៀវហាន ស៊ុនគុង នាំទិសឯជើង ឲ្យស៊ិនកៀនលើកទាហានទៅវាយខាងទិសឯត្បូង ឯដូហ៊ាឯងក៏លើកទៅវាយបន្ទាយពីទិសខាងលិច ទុកតែច្រកឲ្យចេញទៅ បានខាងទិសឯកើតក្នុងខណៈនោះស៊ិនកៀនពាក់ផែនឡើងជិះចូលទៅក្នុងស្រុកអន្ទសៀមបានហើយដេញចាក់កាប់សម្លាប់ពួកចោរលើបន្ទាយស្លាប់ប្រហែល ២០ នាយពួកចោរទាំងឡាយក៏ធ្លាក់ធ្លាក់បែកបាក់អស់ទៅ ។

តៀវហាន ឃើញស៊ិនកៀនពាក់ផែនស្រុកឡើងទៅកាប់សម្លាប់ពលទាហានឲ្យស្លាប់ក៏ខឹងខ្លាំងណាស់ ស្ទុះឡើងសេះកាន់ដាវចូលប្រយុទ្ធគាត់និងស៊ិនកៀន ដល់ច្បាំងកាត់ផែន ស៊ិនកៀនឃើញដូច្នោះក៏ លាក់ខ្លួនពីលើសេះដោយកំឡាំងនឹងហើស ស្ទុះទៅដណ្តើមយកដាវពីតៀវហានបានហើយកាប់តៀវហានធ្លាក់ពីលើសេះស្លាប់ ចាប់យកសេះនោះមកជិះហើយ

ចរបំផាយដេញកាប់ពួកចោរបែកខ្ចាយអស់ទៅ ខានស៊ិនគុនក្រឡេកមក ឃើញថាគស៊ូនឹងស៊ិនកៀនពុំបាន ក៏បរសេះស្ទុះនាំពួកចោរទាំងនោះ ចេញតម្រង់ទៅទិសឯជើង លុះក្រឡេកឃើញឡៀពីកយ៉ទំលាយទ័ពជាប់ ចូលមក ស៊ិនគុនក៏យស្លុតគិតថា អញត្រានេះមុខជាដោះមិនរួចនឹងដៃ ឡៀពីហើយ ត្រូវតែប្រឹងឲ្យខានតែរួចជីវិតចុះ ស៊ិនគុនក៏បកថយក្រោយ ឡៀពីចូលយិតធ្នូបាញ់សំដៅទៅត្រូវស៊ិនគុនធ្លាក់ពីលើសេះស្លាប់ ។

ជូហ៊ឺឃើញបានការ ក៏ដេញសង្គ្រាមបានពាទំលាយបន្ទាយវ៉េយ យកស្រុកបាន ហើយតាប់សម្លាប់ពួកចោរស្លាប់ប្រហែលមួយម៉ឺនប្លាយ ស្រេច ហើយក៏លើកចេញទៅវ៉េយយកស្រុកជាលំដាប់ ។ អម្បាលពួក ចោរដែលវ៉េយយកបានពីថ្ងៃមុនប្រមាណ ២៤ ឬ ៣៥ ស្រុក នោះជូហ៊ឺក៏យក បានវិញទាំងអស់ ឯអាណាប្រជានុរាស្ត្រ សការដែលខានគ្រប់ដែន ដងនៃ ក៏បានត្រឡប់មករក្សាសប្បាយដូចដើម ហើយជូហ៊ឺក៏លើកទ័ពត្រឡប់ ចូលទៅទីក្រុងឡកកែង ថ្វាយការសោទុក្ខថល់សេនាបតី ឲ្យយកសេចក្តី ក្រាបបង្គំទូលព្រះចៅឡេងទេក សូមទ្រង់ជ្រាប ។ ព្រះចៅឡេងទេ ត្រាស់ឲ្យបំណាប់រង្វាន់ជូហ៊ឺ ឡើងទីជា តាយ៉ឺ ហាន ជំមានតំណែងចូល គាល់ពលទុកាស នឹងទ្រង់តាំងឲ្យជាចៅហ្វាយស្រុកហោឡាំទៀត ។ ជូហ៊ឺក៏ក្រាបបង្គំទូលស្ញើសរសើរកិត្តិគុណ ស៊ិនកៀន នឹងឡៀពី ដែលបាន តាំងចិត្តសុចរិតជួយធ្វើការកម្ចាត់ពួកចោរកំណាចគ្រប់ប្រការ ។ ព្រះ

ចៅឡេនគេក៏ទ្រង់ព្រះមេត្តាប្រោសតាំង ស៊ុនកៀន ជាទីក្រម្ការវេត្រ តែ
ឡេវពីនោះមិនបានត្រាស់ថាប្រការម្តេច នោះឡេវពីក៏ថយមករង់ស្តាប់
ការប្រហែល ១ ខែឆ្ងាយ មិនបានសម្រេចសេចក្តីប្រាថ្នាក៏នឹកទោមនស្ស
តូចចិត្តណាស់ ថ្ងៃមួយឡេវពី គួនអ៊ូ គៀវហ៊ុយនាំគ្នាដើរមើលរបៀបទី
លំនៅផ្ទះផ្សារផ្សាក្នុងទីក្រុង ដើម្បីឲ្យរំសាយសេចក្តីខាន បានដើរទៅ
ប្រទះនឹងគៀវគិនជានាម៉ឺនហ្វូងជិះរទេះមក ឡេវពីមានសេចក្តីត្រេកអរ
លើកដៃឡើងគំនាប់ហើយជំរាបថា ខ្ញុំបាទនេះ មានសេចក្តីខឿយហត់ជួយ
ធ្វើពលការរក្សាសេចក្តីសុខ ក្រាដែលស្រុកកើតចលាចលនឹងពួកចោរ
ប៉ុន្តែនឹងរកអ្នកឯណាទូលស្នើសរសើរគុណតាប់ដោះគ្មានសោះ គៀវគិន
បានស្តាប់ដូច្នោះ ក៏រំជួលចិត្តករុណាតឡេវពីណាស់ ទើបនាំឡេវពីចូល
ទៅក្រាបបង្គំគាល់ ហើយទូលព្រះចៅឡេនគេថា កើតពួកចោរជួតក្បាល
លឿងឡើងក្នុងគ្រានេះព្រោះហេតុព្រះអង្គទ្រង់ជឿស្តាប់ពាក្យខន្ទី១០នាក់
ខន្ទីប្រើអំណាចកាត់សេចក្តីអាណាប្រជានុរាស្ត្រទាំងឡាយដោយអស័ត្យ
យកត្រូវជាខុសយកខុសជាត្រូវ បណ្តានាហ៊ឺនមុខមន្ត្រីតូច-ធំដែលនិយម
ខាងផ្លូវយុត្តិធម៌ ក៏ទ្រង់លំអៀងឲ្យដកបុគ្គលចេញពីរាជការ ស្រាប់តែ
សំណូកសូកប៉ាន់គ្មានកៀនខ្មាស មនុស្សវេស្តផ្តាសទ្រង់លើកយកមក
តាំងជាមន្ត្រីគ្រប់តំណែង ហេតុនោះឯង ទើបកើតចលាចលកក់
ស្រុកអស់បណ្តាពស្ត្រសឹងប្រាសចាកសេចក្តីសុខមានតែទុក្ខក្តៅក្រហាយ

ហេតុផលនៃប៉េសក្តីថ្ងៃនេះ ។ ទូលព្រះបង្គំជាខ្ញុំគិតថា នឹងសុំព្រះរាជ-ទានយកខ្ទីទាំង ១០ នាក់ទៅកាត់ក្បាលផ្លាលការក្រោស ឲ្យការណ៍ប្រជានុកស្រ្តទាំងពួងគ្រប់ខែត្រខណ្ឌដែលបំណុះស្រុកហ្វូងបានឃើញជាអស្ចារ្យ បើអ្នកឯណាមានប្រាជ្ញាស្មារតីប្រកបដោយសេចក្តីស័ត្យសុចរិតយុត្តិធម៌គួរប្រាសតាំងជាមន្ត្រីមានឋយសបណ្ដាសក្តិតាមគុណានុរូបទៅ ទើបស្រុកទេសនឹងបាននៅដោយសេចក្តីសុខក្សេមក្សាន្ត ។

ខ្ទី ១០ នាក់ក៏បាននៅគាល់ក្នុងទីនោះ លុះបានឮពាក្យគៀតិនទូលដូច្នោះ ក៏ធ្វើយទូលតាស់ព្រះចៅឡូនតេថា គៀតិនគ្រាន់តែជាទីមន្ត្រីថាត់តាបតូច ហេតុអ្វីពោលបង្កាច់មិនគោរពខ្លាចព្រះរាជអាជ្ញាបួលមកក្រាបបង្គំទូលព្រះករុណាជាពាក្យរំពុកប្រដៅដូច្នេះ ជាការមិនគួរណាស់ ។ ព្រះចៅឡូនតេក៏តាស់អញ្ញាស្រីយ ទើបត្រាស់ឲ្យពេជ្ឈឃាដបណ្ដេញគៀតិនចេញចាកទីគាល់ ទើបខ្ទី ១០ នាក់គិតគ្នាថា គៀតិនមកក្រាបទូលពោលទោសយើងក្នុងវេលានេះជាខុសធំណាស់ ប្រហែលជាបានចេញទៅធ្វើការបង្ក្រាបពួកចោរ មានសេចក្តីនឿយហត់ប្រាកដដោយគុណបំណាច់ល្អមែន ហើយគ្មាននរណានឹងទូលស្មើសរសើរគុណគាប់ឲ្យ បានជាទឹកតូចចិត្តមកចូលមកទូលពិតខ្លួនឯងដូច្នេះ លុះយើងនឹងឲ្យធ្វើទោសគេបត្រានេះ សេចក្តីនិន្ទាគង់

មានដល់យើងមិនខាន បើដូច្នេះ យើងត្រូវតែគិតការដោយស្ងាត់ នឹងសម្លាប់បង្ខាត់ជីវិតគេចេញ កន់មិនរួចពីដៃយើងទេ ។

ព្រះចៅឡុងគេ លើបទ្រង់ព្រះតំរិះថា ឡៀតក៏មានសេចក្តីភាប់ ប្រសើរក្នុងឧបការ ទើបត្រាស់ឲ្យសេនាបតីឲ្យបំណាច់ឆ្លាន់ឡៀត សេនាបតីយល់ព្រមត្រូវតាំងឡៀតឲ្យចេញទៅធ្វើចៅហ្វាយស្រុកអាន់-ហាគុន ទើបឡៀតឲ្យទាហានដែលមកជាមួយវិលត្រឡប់ទៅស្រុកទេស វិញអស់ រើសយកតែមនុស្សស្និទ្ធ ចំនួន ២០ នាក់ ហើយនាំគ្នីគ្នា ទៀវហ៊ុយនឹងមនុស្ស ២០ នាក់ទៅឯស្រុកអាន់ហាគូនបានប្រហែល ១ ខែប្លាយ ឡៀតក៏ចាត់ការសេចក្តីចប់ការដល់អាណាប្រជានុរាស្ត្រថា បើ អ្នកណាកើតក្តីការស៊ីនឹងគ្នា មានកែផ្សះផ្សាឲ្យគិតថយចុះទៅជាលំដាប់ ពាស្ត្រទាំងពួងក៏បានសេចក្តីសុខក្សេមក្សាន្តមានសេចក្តីស្រឡាញ់ចប់ការ លើកដៃសំពះសរសើរឡៀតថា ល្អណាស់ដូចជាមាតាបិតា ឯគ្នីគ្នា ទៀវហ៊ុយ ក៏មានចិត្តគក្តីមេត្រីស្រឡាញ់ឡៀតដោយស្មោះត្រង់ពេល ដែលឡៀតចេញទិយាយកដការ ក្នុងគ្នី ទៀវហ៊ុយ ក៏មិនដែលឃ្លាត បាត់មុខសោះ តែនឹងស្រ្កាក់គិតក្តីក្សេក្សា ។ លុះនៅយូរមកមាន សំបុត្រព្រះឯកម្ចាស់ត្រាស់ប្រើក្មុំដោព្រះពជបំរើឲ្យនាំមកដល់ឡៀត សេចក្តីថា បើជាស្ត្រានបានឡៀតនឹងចំដាមទ្រង់ចៅហ្វាយស្រុក ហើយ ត្រូវនាំស្មួយសារឡៀនមកណាខាងក្នុង ឡៀតពីងឹងដំណើរក៏ចេញ

ទៅទួលផល់ទ្វារស្រុក ឡេវ៉ាពីក៏ទាប់ព្រះកេវត ម្ចាស់តាមទំនៀម ហើយសួរព្រះកផុចពីពីទកដកា ផ្សេងៗ គុគ៊ីវធ្វើឬតតាមិតគោតក្រែង ឡេវ៉ាពីប្រាប់ទ្បផការ ហើយយកសៀបឆ្អីបេមុខឡេវ៉ាពី ។ គួទគ៊ូ គៀហ៊ុយ ឃើញផ្លូវបោះទីឆ័យណាស់ តែមិនទេញក៏ចាជាម្តេច ហើយឡេវ៉ាពីអញ្ជើញ គុគ៊ីវឡើងទៅគុងផ្ទះបាត់ទឹកថ្ងៃឱ្យនៅតាមទំនៀម ឯគុគ៊ីវអង្គុយលើទ ខ្ពស់ឲ្យឡេវ៉ាពីឈរគំនាប់តាមគំណែង គុគ៊ីវសួរឡេវ៉ាពីថា អ្នកឯងមាន គុណគាប់គ៊ីខ្ទះធ្វើបបាទដកម្ពុំទៅញាយស្រុកនេះ? ឡេវ៉ាពីឆ្លើយថា ខ្ញុំជា ពូជព្រះវង្សត្រកូលហោ ទគ្គប តែជាបុគ្គលក្រសោតិច ទើបបានជាអ្នកតួប នៅស្រុកទុនតួន កាលត្រាកើតពួកចោរជួតក្បាលលឿងជាពួកក្បត់នោះ ខ្ញុំក៏បានយកកាសាផែនដីថេញទៅបព្វជិតកាបោរដល់ ៣៤-៣៥ ដង មានគុណបំណាច់តិចតួចណាស់ ទើបទ្រង់ត្រាសឲ្យបេញមកគេក្បស្រុក នេះ ។ គុគ៊ីវបានឮផ្លូវឈ្មោះកៅស្រុកដំហិកឱ្យឡេវ៉ាពីថា ឯងនេះទ្រង់ទសក្តិ អ្នកអាងថា ខ្លួនជាព្រះញាតិវង្ស ហើយអ្នកថា ខ្លួនបានទៅបង្ក្រាបត្រួច ពួកចោរដល់ទៅ ៣៤-៣៥ ដងទៀត យើងគន់មើលរូបកាយមិនសម ជាអ្នកធ្វើការសឹកទេ កុំនិយាយកុហកយើងមិនជឿខ្លួនទេ ដែលមិនធ្វើ ជាអ្នកគេក្បស្រុកនេះគួរហើយ ឥឡូវមានព្រះកម្រាស់ឲ្យយើងមកទាលោត សួយសារជាដំនួសគំណុកនទែវក្រាំ ។ ឡេវ៉ាពីស្តាប់ហើយ ក៏នៅស្ងៀម មិនតបសោះ ទើបណាពុះទៅកាន់ទីលំនៅ ហើយឲ្យហៅបាឡាត់ស្រុក

មកប្រឹក្សាថា តុអ៊ីជាព្រះកជបំរើមកបន្ទាប់ដូច្នេះ យើងនឹងគិតដូចម្តេច។ បាឡាក់ឆ្លើយថា តុអ៊ីធ្វើក្អេងក្អាងដូច្នេះ ប្រាថ្នានឹងយកសំណូកជាប្រយោជន៍ខ្លួន ទៀតពីគបថា តាំងពីយើងមកឈរនៅស្រុកនេះថ្ងៃចំនៀមគ្មាន យើងមិនដែលទៅបៀតបៀនអ្នកឯណាឲ្យបានអំបោះមួយសរសៃ មួលមួយក៏ឥតអន្តិមាន យើងមិនដែលធ្វើឲ្យបណ្តាលស្រុកក្តៅក្រហាយសោះ បើដូច្នេះនឹងមានរបស់អ្វីមកឲ្យសំណូកដល់តុអ៊ី នោះយើងក៏តាល់គំនិត ។

លុះព្រឹកឡើងតុអ៊ីឲ្យហៅខ្លួនបាឡាក់ស្រុកទៅផង ហើយគយប្រាថ្នាឲ្យបាឡាក់ឆ្លើយថា ទៀតពីធាកស្រ្ត បាឡាក់មិនបានឆ្លើយតាមពាក្យតុអ៊ីកំទេ ទៀតពីជនក៏រៀបនឹងចូលទៅរកតុអ៊ី អ្នកចាំទ្វារពាំងឃាត់មិនឲ្យចូលទៅ ទៀតពីត្រឡប់ទៅវិញ វេលានោះគៀវហ៊ុយផឹកស្រាស្រវឹងណាស់ ក៏ជិះសេះចរទៅលេងទៅដល់ត្រង់មាត់ទ្វារដែលតុអ៊ីនៅ ឃើញមនុស្សចាស់ៗឈរស្រែកយំប្រហែល ៥០-៦០ នាក់ គៀវហ៊ុយផាកទៅសួរថា ហេតុអ្វីអ្នកពល់គ្នាមកឈរយំនៅទីនេះ? មនុស្សពួកនោះ ក៏ជំរាបថា តុអ៊ីឲ្យយកបាឡាក់ទៅចងកយហើយបង្ខាប់ឲ្យឆ្លើយថាទៀតពីធាកស្រ្ត យើងខ្ញុំបបួលគ្នាមកសុំទោសលោកបាឡាក់ អ្នកចាំទ្វារមិនព្រមបើកឲ្យចូលទៅថែមទាំងគយដំយើងខ្ញុំឡើងទៀត យើងខ្ញុំមានសេចក្តីឈឺចាប់គៀនខ្នាសទើបស្រែកយំដូច្នេះ ។

តៀវហ៊ុយ បានស្តាប់ហើយ ក៏ខឹងខ្លាំងណាស់ លោតចុះពីលើខ្នងសេះស្ទុះទៅត្រាទ្វារ នាយទ្វារហាមឃាត់ក៏មិនព្រមស្តាប់ លុះតៀវហ៊ុយ ចូលទៅដល់មាត់ទ្វារឃើញបាឡាត់ត្រូវបំណាក់ចាំងជើងវៃ ឃើញគុយអ៊ីអង្គុយលើកៅអី តៀវហ៊ុយស្រែកគំហកថា អាឯងនេះជាមនុស្សចកស្ត្រខ្លាំងណាស់ អាឯងស្គាល់អញដែរឬទេ ៗ គុយអ៊ីភ័យស្លុតស្មារតីងើបឡើងមើលឃើញតៀវហ៊ុយមិនទាន់ច្វេតថាម្តេច តៀវហ៊ុយស្រាប់តែចាប់កន្ទាក់សក់ទាញទម្លាក់ពីលើកៅអី ហើយយកសក់រុំក្របូចនឹងដៃអូសទាញចេញមកដល់សាលាកណ្តាល ហើយយកសក់គុយអ៊ីចងភ្ជាប់នឹងបង្គោលសេះ រួចកាច់មែកឈើស្រល់មកវាយសំពន់គុយអ៊ីទាល់តែដំណំត្រាំត្រា ៗ ចាលឡេវពីត្រឡប់វិលទៅផ្ទះវិញក៏អង្គុយកើតទុក្ខទោមនស្ស លុះឮសំឡេងគុយអ៊ីស្រែកនោះឡើង ក៏សួរមនុស្សម្នាថា សំឡេងនរណាស្រែកអ៊ូខ្លាំងម្ល៉េះ មានគេជំរាបថា សំឡេងតៀវហ៊ុយចងគុនជាមួយនោះយកនរណាទៅវាយមិនច្បាស់ប្រាកដ ៗ ឡេវពីពិតកាល់ក្នុងចិត្តក៏ដើរចេញទៅមើល ឃើញតៀវហ៊ុយកំពុងតែវាយសំពន់គុយអ៊ីនៅក្នុងចំណង ឡេវពីភ័យណាស់ស្ទុះទៅឃាត់តៀវហ៊ុយ ៗ ថា អានេះជាមនុស្សចេះបាតធំណាស់ វាជាមនុស្សអាក្រក់ខូចវាមិនបានទេសមតែវាយឲ្យស្លាប់ ៗ គុយអ៊ីឃើញឡេវពីមកដល់ក៏និយាយអង្វរថា សូមលោកជួយដោះជីវិតខ្ញុំផង ឡេវពីឮដូច្នោះក៏មានចិត្តមេត្តាអាណិត ក៏និយាយ

ឃាត់ហាមគៀរហ៊ុំចឲ្យដើរចេញ ទទួលគ្មានអ្វីដាំមេចផល់ទៀត ដើម
និយាយទាំងឡាយថា យើងបានផ្ទះបក្ខគាប់ប្រសើរយ៉ាងណាណាដែលជី
មធម្មជាច្រើនគ្រាហើយ ក៏បានហាមនូវទ្រឹមប៉ុណ្ណោះ តែគ្រូរបស់ព្រះពុទ្ធ-
បំរើមិនមើលងាយ ក្រៅពីមុខការព្រះពុទ្ធបំរើមុខគួរឲ្យមានសេចក្ដីស័ង
យសណាស់ ដែលយើងបង្កើនតែ ៣ នាក់ ឧបមាដូចជាសត្វហង្ស
ដែលទាំងគាស្រួយទៅកន្លែងព្រៃរម៉ិនសមគួរ សោះ បើដូច្នេះយើងត្រូវតែ
សម្លាប់គុរុនេះហើយ ទាំងបបួលគ្នាទៅនៅក្រៅរោងសរបស់យើងវិញ
ប្រសើរណាស់ ដំណាលទៅមុខសិម.យើងទិនិតកការដកទៅ ។ ឡើងពីបាន
ស្ដាប់ក៏ចាប់ចិត្តផ្សែងត្រូវទាំងគំនិតរបស់ខ្លួន ចើមក្រឡុះទៅផ្ទះឫលទៅ
យកត្រាសម្រាប់ផ្ការមកបងក្កុរ ហើយផ្ដាំថា ឯងជាព្រះពុទ្ធបំរើមក
ផ្ញើផ្ការលោកដោយអាការៈហែងតបំកិតបំភ័យដូច្នេះ គួរណាស់តែយើង
ទាំងកាត់ក្បាលឯងចេញ សឡូរយើងទុកជីវិតឯងវិញដោយចិត្តយើងល្អ
យើងក៏មិនត្រូវការទាំងនៅផ្លូវផ្ការក្ដីនេះទេ ឯងហូរទាំយកត្រានេះ
ចូលទៅស្រុកក្រុងរន្ធាប់ យើងវិលទៅវត្តស្រុកទេសវិញហើយយើង
ហើយ ហើយទៀតក៏នាំគ្នាអ្វី ទៀតហើយ រំលងគ្នាពួកហាង ២០ នាក់
នោះចេញអំពីស្រុកនាំបានគ្នាទៅ ។

ឯគុរុក៏នាំយកត្រាសម្រាប់ផ្ការ ឡើងពីទីរំលងពួកចេញទៅដល់
ស្រុកកេនដាវដាំមណ្ឌលបេក្ខ ។ (មានត)

# ប្រវត្តិសាស្ត្រប្រទេសចិន

ហ្វុងមិត្តទួមទ្រី ញ៉ុក-ថែម ប្រែរៀបរៀង

(តមក)

---

វិញ្ញាណរបស់ព្រះអង្គប្រឡាក់ទៅដោយលោភផលណ្តួតពេញទៅ ពីព្រោះក្រោយផែនត្រឡប់មានទៀតឡើយ ។ សម័យនេះជាវេលាសម័យនៃ ព្រះកដ្ឋឲ្យានជំទៀតស្រអាក់ស្រស់បស់ទឹងមិនមានឡើងវិញទៀត ឬ?

តាមដោយពិតនោះ ផតាសីនៃកជវង្សហាំងមិនទាន់អស់សង្ឃឹម នោះនៃមួនទេ ព្រោះទុកជាអ៊ាន-លោឆាន មេឡូត្របូលមកដណ្តើមយក ក្រុងស៊ី-អ៊ានទៅបានហើយក៏ដោយ ព្រះរាជស៊ូ-សុងដែលត្រូវកដ-សម្បត្តិជាដំណតមកក៏នៅមានសង្ឃឹមលើកឡាំងតទល់ទ័ពទៅទាន់កាន-ស៊ូ ដែលមានពួកតាហានពួកអ៊ីន់អ្នកចម្បាំងដាច់ពាស់របស់ពួកតាតារ សង មានចិត្តស្មោះស្ម័គ្រនឹងរាជវង្សហាំងនៅឡើយ ។ កងទ័ពនេះមានមេទ័ព ដែលពូកែ ២ នាក់គឺគួសៀនិងលីគួងពី ដែលស្ម័គ្រចិត្តជាប់ជាតែស៊ូ បើក្បីព្រះរាជាធិរាជ ក្រៅអំពីនេះនៅមានជំនួយពីស្រុកផ្សេងៗទៀត ដែលសំខាន់ជាងគេ គឺពួកហួយកូជាពួកមួយពួក ដែលបានលើកទ័ព ចូលមកជួយហើយដណ្តើមយកក្រុងស៊ី-អ៊ាន និងលោយ៉ាំងបានត្រឡប់ មកវិញ កាលពីពុទ្ធសករាជ ១៣០០ អ៊ាន-លោឆានក៏ដល់អនិច្ចកម្ម ទៅ ។ ពួកក្បត់មិនទាន់បានលប់រាបស្ងប់នៅទេ ព្រោះនៅមានមេទ័ពនឹង

មកនាំបំបះបំបោរយ៉ាងខ្លាំងតទៅទៀត ហេតុដល់មកក្នុងពុទ្ធសករាជ ១៣០២ ទើបពួកក្បត់ផ្ដើមយកស្រុកលោ - យ៉ុងត្រឡប់ទៅវិញបាន ហើយរាយលុកលុយចូលដល់ស្រុកញូ ណាន ពួកហ្វូ - ក្វីត្រឡប់មកជួយទៀត ហើយបណ្ដេញពួកក្បត់ឲ្យថយទៅវិញបានក្នុងពុទ្ធសករាជ ១៣០៦ ក្នុងខណៈដែលថយទៅនោះ ពួកក្បត់បានដុតទីក្រុងនាំងមួយស្ទើរមិនមានអ្វីសេសសល់នៅឡើយ ។

ពួកក្បត់បានស្ងប់ស្ងាត់ទៅមួយគ្រា ប៉ុន្តែអំណាចចិននៅទ្វីបអាស៊ីវេលានោះសាបសូន្យអស់ទៅហើយ ក្នុងវេលា ៧ ឆ្នាំដែលកើតបះបោរឡើងក្នុងស្រុកនោះ ពួកទីបេក៏មានកងទ័ពខ្លាំងពូកែឡើងយ៉ាងរួសរាន់ តាល់តែមានកងទ័ពលួចចូលមកពីក្រុងស៊ុំ - ង៉ាន ក្នុងឆ្នាំពុទ្ធសករាជ ១៣០៦ តែត្រូវកងទ័ពតកួសៀបណ្ដេញទៅបាន ក្នុងឆ្នាំតទៅមក ពួកទីបេក៏បះតែរុករានចូលស្រុកចិនមិនស្រាកតាល់តែចូលដល់ខេត្តកាន - ស៊ូ ហើយកាត់គមនាគមន៍រវាងប្រទេសចិននិងទ្វីបអាស៊ីកណ្ដាលដាច់ចេញពីគ្នា ។ ឯព្រះបាទស៊ូ - សុងក៏ទិវង្គតទៅតាំងពីឆ្នាំពុទ្ធសករាជ ១៣០៥ រួមវេលាដែលគ្រងរាជសម្បត្តិ ៧ ឆ្នាំ ។ ព្រះមហាក្សត្រដែលគ្រងរាជ្យជាតំណតមក ទ្រង់ព្រះនាមព្រះបាទថៃ - សុងទី ២ នៅគ្រងរាជសម្បត្តិអស់វេលា ១៨ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ១៣០៥ ដល់ពុទ្ធសករាជ ១៣២២ ហើយតមកព្រះរាជឱរសរបស់ព្រះបាទ

ថៃ-សុង ទី ២ ទ្រង់ព្រះនាមថា តេ-សុង គ្រប់គ្រងរាជសម្បត្តិតមកទៀត រហូតដល់ពុទ្ធសករាជ ១៣៤៨ ។ រហូតវេលាអម្បាលណោះ ពួកទីបេត៍ បានបង្កការបោលបោករើកដល់ចិនមិនមានស្រាកស្រាន្តឡើយ ទាល់តែចិនតោងទៅសុំកំឡាំងទាហានពីពួកឥស្លាមឧយហ្គួរៗ ឲ្យជួយដោះទុក្ខចិនមកហើយ ក្នុងគ្រានេះព្រះបាទតេ-សុងទ្រង់ព្រះរាជ-ទានស្ត្រីប្រុសស់ម្នាក់ដល់ក្សត្ររបស់ពួកឃុយហ្គួ ទើបបានកំឡាំងទ័ពមកប្រាបប្រាមពួកទីបេត៍បានស្រេច កាលពីពុទ្ធសករាជ ១៣៣៤ ។ ឯពួកទីបេត៍នោះទុកជាខាងដើម មានកំឡាំងរឹងប៉ុនយ៉ាងណា តែតមកគ្រាក្រោយៗ ក៏ខ្សោយបោះកំឡាំងទៅ ទើបធ្លាក់មកសុំធ្វើស្ពានមេត្រីមួយដងចិនវិញ ក្នុងឆ្នាំពុទ្ធសករាជ ១៣៦៤ ។ ក្រោយចិនបាលបើបានអស់សិកសត្រូវអាក់ទីបេត៍ ក៏ត្រឡប់ជាមានសត្រូវថ្មីកើតឡើងទៀត គឺពួកណាំន-ចៅ ជាខ្សែស្រឡាយជាតិថៃដូចពោលមកហើយ ។ ក្នុងឆ្នាំពុទ្ធសករាជ ១៤០៩ ពួកណាំន-ចៅ បានដណ្តើមយកតុង-កិងពីចិនទៅបាន តែតមក ៣ ឆ្នាំទៀត ចិនក៏វាយត្រឡប់យកទៅវិញបាន ដោយមានមេទ័ពប្លែកម្នាក់ឈ្មោះកៅ-ពៀន ខាងយួនប្រកាន់ថា កៅ-ពៀននោះជាវីរបុរសជាតិយួន (មិនមែនចិន) ។ ឯពួកណាំន-ចៅ ក៏មិនទាន់ស្ងប់នៅត្រឹមណោះទេ បែរជាលើកទ័ពទៅច្បាំងដល់ស្រុកសេ-ឆួន ទើបរដ្ឋបាលចិនហៅគេកៅ-ពៀន ដែលធ្លាប់ច្បាំងឈ្នះពួក

ណាន់-ចៅ អំពីដែនគុង-ភិន ឲ្យទៅជាការត្រួតត្រាមពួកណាន់-ចៅ កៅ-តៀនបានកាយបែកវាយពួកណាន់-ចៅសម្រេចទៀត ក្នុងឆ្នាំពុទ្ធសករាជ· ១៤២០ ហើយពួកណាន់-ចៅចងស្ពានមេត្រីនឹងក្រុងចិន ។

ពង្សាវតារចិនមកដល់ចំណែកនេះនាំឲ្យយើងមើលឃើញថា ទុកជាស្រុកចិនកើតសោកសោយទៅយ៉ាងណាក៏ដោយ រាជវង្សថាំងនឹងដល់ទូវសេចក្តីវិនាសសាបសូន្យក្តី ក៏មិនមែនដោយសារខ្វះកំឡាំងកងទ័ពទេ ប៉ុន្តែសេចក្តីសោកសោយរៀងក្រោយដែលកើតឡើងនោះក្រុងចិនមានចំនួនដូចជាក្រុងកេម ក៏ពួកមេទ័ពដែលមានកំឡាំងទាហាននៅក្នុងដៃនាំគ្នាតាំងខ្លួនជាក្សត្រគ្រប់ផងស់ ពួកមេទ័ពខាងក្រុងស៊ុ-ង៉ាន, ប៉េជិលី, ចាន-ស៊ី, កាន ស៊ូនិងសេ-ឈួន សឹងមានចំណាំងចង់បានរាជបល្ល័ង្ករបស់ក្រុងចិនទាំងអស់គ្នា សឹងមានបមសានកែរៀងខ្លួនថា ខ្លួនជាអ្នកធ្វើការមកច្រើនបំផុត បានធ្វើប្រយោជន៍ដល់ការពារជាតិបានច្រើនជាងបំផុត ហើយសមគួរនឹងគ្រងរាជបល្ល័ង្ករបស់ចិនបាន ។ ក្នុងសម័យនោះព្រះមហាក្សត្រក្នុងរាជវង្សថាំងនៅគ្រប់គ្រងក្រុងចិននៅឡើយ ក៏ប៉ុន្តែលោហិតរបស់ព្រះបាទថៃ-ស៊ុងមហារាជតាមតែសាបរលាបអស់ទៅហើយ ព្រះមហាក្សត្រយ៉ាងក្តីក្រោយៗ សឹងសុទ្ធតែកណ្តាប់ដៃរបស់ពួកនាម៉ឺនមន្ត្រី ស្រេចតែពួកនេះនឹងចាប់ផ្តិលទៅខាងណាក៏បានតាមចិត្ត ។

តមកក្នុងឆ្នាំព្រះសករាជ ១៤១៨ មានកើតចលាចលវឹកវរឡើងយ៉ាងធំក្រៃលែង នៅខេត្តដែនបើដីល័ខឹងពានគុង មាន មេទ័ពដែលខ្លាំងពូកែម្នាក់ឈ្មោះហ្វូង-ពៅ ក្នុងបក្សការបះពលបះបោរឡើងបានបង្ក្រាន់រុកទន្ទ្រានហូតដល់ស្រុកកាំង-តាំង រួចយកកាំង-តាំងបានក្នុងឆ្នាំព្រះ-សករាជ ១៤២២ ហើយឡើងមកវាយស្រុកណា-យ៉ុង និងក្រុងស៊ុ-ម៉ាន បានក្នុងឆ្នាំព្រះសករាជ ១៤៤៤ កាលបើកើតភ័យអន្តរាយនាក្នុងស្រុកឡើងដូច្នេះ ពួកការចិនក៏ងាកតែងធ្វើការដូចធ្លាប់ធ្វើពីមុនៗមក ។ គឺសុំកំឡាំងពីពួកកុក ក្នុងពេលនេះមានពួកមួយពួកហៅថា កាគូ មានប្រមុខឈ្មោះលីកេយ៉ង បានកួលមកតាំងនៅខាងជើងខេត្តបាន-ស៊ី ទទួលយកអាសារដ្ឋបាលចិនបង្ក្រាំងដណ្ដើមយកស្រុកណា-យ៉ុងនិងស៊ុ-ម៉ានពីហ្វូង-ពៅមកបាន ហើយសម្លាប់ហ្វូង-ពៅសម្រេចកាលពីព្រះសក-រាជ ១៤២៦ ផង ។

ឯរដ្ឋបាលចិនបានលើកខេត្តបាន-ស៊ីទាំងមូលឲ្យទៅលីកេ-យ៉ង ដើម្បីជាសាគុណបំណាច់ក្នុងការប្រាបប្រាមក្បត់ទាំងនោះៗ ចំណែកខាងកងទាហានរបស់ហ្វូង-ពៅនោះនៅក្រោមត្រួតត្រារបស់មេទ័ពនេះឈ្មោះជូ-វេនឡាធុះព្រមទទួល នៅជាចំណុះរដ្ឋបាលចិនដោយស្រួលបួលរដ្ឋ-បាលចិនមានសេចក្ដីពេញចិត្តចប់ប្រគល់ស្រុកថៃ-ហ្វុង ក្នុងខេត្តហ្វូ-ណានឲ្យទៅផ្គាំផ្គង ។ ការដែលរដ្ឋបាលចិនធ្វើបែបនេះនាំឲ្យ

រាជវង្សថាំងការទៅតែចាប់សាបសូន្យ ហ័ស ឡើងទៀត ព្រោះអំណឹះតមក ៤៥ ឆ្នាំទៀតគឺក្នុងពុទ្ធសករាជ ១៤៥០ ជូ-វេនអេះឯងមានអំណាចឆាត់ធំឡើងយ៉ាងសំបើម ដល់ទៅមានអំណាចដកព្រះមហាក្សត្រក្នុងរាជវង្សថាំងអង្គក្រោយបំផុតចេញពីរាជសម្បត្តិ ហើយតាំងខ្លួនឯងឡើងជាព្រះរាជាធិរាជ តាំងរាជវង្សក្សត្រថ្មី ហៅថា ហៅ-លៀង ហើយតាំងទីក្រុងនៅស្រុក ខៃ-ហ្វុង ឯរាជវង្សថាំងក៏ដល់អវសានផុតរលត់ត្រឹមណោះទៅ ។

ឆ្នាំពុទ្ធសករាជ ១៤៥០ ជាឆ្នាំដែលរាជវង្សក្សត្រចិនដ៏ធំបំផុត ដែលបានគ្រប់គ្រងស្រុកចិនមកជាវេលាដល់ ២៨៩ ឆ្នាំ ហើយធ្វើឲ្យបានសេចក្តីចំរើនថ្កុំថ្កើងដល់ប្រទេសចិនទាំងខាងអំណាច ទាំងខាងការប្រជុំ ទាំងខាងសិល្បសាស្ត្រនិងអក្សរសាស្ត្រទាំងឡាយ ត្រូវវិនាសផុតអស់ត្រឹមណោះឯង ។ (មានត)

# រឿងស៊ុន-យ៉ាត់-សេន

## អ្នកនយោបាយឯកជាតិចិន

លោក ក៉េ-ប៊ុក ប្រែពីភាសាបារាំង

(តមក)

---

បានកូលះទៅជំរាបលោករដ្ឋមន្ត្រី គុង-តា-ជេង (Kung-Ta-Jen) ហើយក៏បានពន្យល់ថា លោក «ឡ៉ឺតសាលីស្ប៊ូរី» បានបង្ខំឲ្យដោះលែងលោកស៊ុន-យ៉ាត់-សេន” ។

ខ្ញុំមិនបានយល់ឃើញចរិយាលោកហាលីដេម៉ាកាទី ខ្ញុំសូមប្រគល់កិច្ចនេះចំពោះមតិមហាជននិងមនោគតិ (Conscience) របស់មហាជន ក្នុងប្រាជ្ញារបស់លោក ៗ មានមតិដើម្បីនឹងឆ្លើយដោះសាឲ្យឃើញថា លោកមានចរិយាដ៏បរិសុទ្ធមែន តែមតិនោះយកជាការមិនបាន ចំពោះមនុស្សដែលមានប្រាជ្ញាមុតមាំ ហើយមានឋានន្តរ តាន់ក្របួនខ្ពស់ ខ្ញុំស្មានថាមិនគាំងបានបង្ហាញពិតប្រាកដខ្លួនមុខមាត់លោកនេះក្នុងពេលមុនថា “លោករដ្ឋមន្ត្រីនៅទីនេះជាចៅហ្វាយនាយតែឈ្មោះ ការទាំងអស់ស្រេចនឹងលោកម៉ាកាទេ”

កាសែតជាច្រើនបានចុះពត៌មានផ្សាយអំពីនយោបាយ ដែលប្រើក្នុងខណៈដែលពួកមិត្តភក្តិខ្ញុំបានជួយសង្គ្រោះខ្ញុំឲ្យរួចរស់ជីវិត ខ្ញុំបានរើសមួយដែលចុះកាសែតឆកពិណនាថ្ងៃបមានសេចក្តីតទៅនេះ ៗ

# យោបល់ដែលប្រើក្នុងកិច្ចសង្គ្រោះ
# លោក ស៊ុន-យ៉ាត់-សេន ឲ្យរួចបាកទោស

“អំពីរឿងចាប់លោក ស៊ុន-យ៉ាត់-សេន យើងបានដំណឹងដោយច្បាស់លាស់ថា មិត្តភក្តិលោកបានធ្វើផែនទីយ៉ាងសាមញ្ញអស្ចារ្យក្នុងវិធីសង្គ្រោះលោកនេះ បើសិនជាក្រសួងហ្វរេញ-អុហ្វិស ហើយនិងក្រសួងស្កុតឡែនយ៉ាដ (Scotland Yard) បានឲ្យដំណឹងជាមុនថា គ្មានអ្នកណាធ្វើទោសប្តូរបាកម្ចាស់លោក ស៊ុន-យ៉ាត់-សេន បើមិនដូច្នោះទេ មុខជាមិត្តភក្តិលោកប្រើយោបល់កាច់បំបាក់បន្ទប់ចន្លូបលោកនេះឲ្យឡើងទៅលើដំបូលគេហដ្ឋានលេខ ៤៩ ហើយនឹងដាក់ក្រោះអគ្គីទាស់ ប៉ុន្តែ មិត្តភក្តិលោកបានឲ្យដំណឹងលោក ស៊ុន-យ៉ាត់-សេន អំពីរឿងផែនទីនេះតិចតួច តែក្មេងម៉ាក់នេះបានដឹងថាលោក ស៊ុន-យ៉ាត់-សេន ជាប់ឃុំនៅតែមានមនុស្សករុណាអាណិតនានា ហើយបន្ទូលឲ្យលោកដែលជាមិត្តភក្តិរបស់លោក ស៊ុន-យ៉ាត់-សេន មានសេចក្ដីសង្ឃឹមថា យោបល់ថ្មីនេះនឹងសម្រេចដូចបំណងមិនខាន យោបល់នេះបានគិតទុកមុនមកយូរហើយ បានតាំងផ្លូវដាក់ជូនយកប្រើឲ្យលោក ស៊ុន-យ៉ាត់-សេន ដោះទៅកាន់ផ្ទះមិត្តភក្តិម្នាក់របស់លោក ស៊ុន-យ៉ាត់-សេន ជាប់លោកនេះស្លៀកពាក់ថែមនូវជាតិអង់គ្លេស អ្នកឯងតាំងពីគេមិនអាចថាជា

ជាតិក្បាប្រទេស ។ គេបានពណ៌នាថាកាលលោកស៊ុន-យ៉ាត់-សេន នៅក្រុងហុងកុង លោកមានចិត្តសប្បុរសហើយមានចរិយាស្លូតត្រង់ក្នុង ខណៈដែលលោកបានធ្វើគ្រូពេទ្យ លោកក៏ប្រសប់ផ្សំឱសថយ៉ាង ចំណាន ហើយលោកបានជួយស្រោចស្រង់ពួកទុគ៌តក្រីក្រលំបាក គេ ស្មានក្នុងចិត្តថាលោកស៊ុន-យ៉ាត់-សេន ជាអ្នកឲ្យគំនិតយោបល់ក្នុងការ បះបោរនៃត្រកូលទាំង ពិតមែនតែលោកមិនសូវពេញចិត្តនឹងរដ្ឋាភិបាលនៃ ពួកកុងបាជ ដែលត្រួតត្រាលើក្វាងទាំងពីរ (des deux Kouangs) ដែលមានបាំងគាបជំលាយអាក្រក់ពន់ពេក ។

ក្នុងរឿងគ្រោងការសង្គ្រោះលោកស៊ុន-យ៉ាត់-សេន នោះក្នុងថ្ងៃ ១៦ ខែតុលាឆ្នាំ ១៨៩៦ បម្រើអង់គ្លេស ឈ្មោះគូលបានសរសេរ សំបុត្រមកលោកកង់ទ្លីថា : « ខ្ញុំមានឱកាសយប់នេះល្មមឲ្យលោកស៊ុន ចេញពីបន្ទប់ឡើងទៅលើដំបូលគេហដ្ឋានមួយ ដែលនៅបន្ទាប់ បើ លោកយល់ព្រម សូមឲ្យដំណឹងម្ចាស់ផ្ទះនេះថា សូមដាក់មនុស្សម្នាក់ ជិតផ្ទះ ដើម្បីចាំទទួលយកលោកស៊ុនចុះពីដំបូល លោកកង់ទ្លីបានយក សំបុត្រនោះទៅជាកប ទៅនាទីក្រសួងស្កុតឡែនយ៉ាដ ហើយសូមឲ្យ តម្រួតក្រមនគរបាលម្នាក់នៅចាំលើដំបូល ។ តែមន្ត្រីក្រសួងស្កុតឡែន-យ៉ាដថា យោបល់បែបនេះមិនត្រូវតាមច្បាប់ហើយ សន្យាថាក្នុងរវាង មួយឬពីរថ្ងៃទៀត លោកឥទ្ធនុញ្ញាតឲ្យខ្ញុំចេញតាមទ្វារធំ ។

# ការដោះលែងលោកស៊ុន-យ៉ាត់-សេន

ថ្ងៃ ២២ ខែអុកតូប្រ៍ ឈ្មោះកូលចេញពីបន្ទប់ បានឲ្យសញ្ញាខ្ញុំមើលក្រែកនៅចង្រ្កានភ្លើង ខ្ញុំទៅមើលបានឃើញក្រដាសកាសែតឈ្មោះ “គ្លូប” ដែលពណ៌នាពីរឿងដែលចាប់ឃុំឃាំង ខ្ញុំបានឃើញថាកាសែតបានជួយគាំរឿងនេះ ខ្ញុំយល់ថាប្រាកដជាខ្ញុំនឹងបានរួចខ្លួនមិនខាន ។

ថ្ងៃសុក្រ ២៣ អុកតូប្រ៍ គំនិតព្រឹកដល់ល្ងាចមិនខានហេតុគេអីទេ ចំណែកខ្ញុំនៅតែជាប់ឃុំឃាំងដដែល ។ លុះដល់ម៉ោង ៤ កន្លះ គ្រូគង្វាលនឹងចិនចូលទៅក្នុងបន្ទប់ខ្ញុំហើយចេញវាចាថា “លោកមាការទទួលជួបលោកខាងក្រោម” គេបានប្រាប់ខ្ញុំឲ្យយកស្បែកជើងមួកការវ៉ែនរបស់ខ្ញុំទៅជាមួយផង ។ ខ្ញុំក៏ធ្វើតាមគេសព្វគ្រប់ការ ខ្ញុំចុះតាមជណ្តើរទៅខាងក្រោមដី ខ្ញុំស្មានថាគេយកខ្ញុំទៅឃុំឃាំងក្នុងគុកដាក់ស្រា ចំកំ គ គ្រួត្រារ៉ែ គេហាផ្លានអក្ខរជដូចចិនដោយខានបង្អាប់ពីរង្គាក់បាលប្រិគាន្ទិក ។

ប៉ុន្តែឃុំបន្តិចស្រាប់តែឃើញលោកគន្ធិ៍ គេហៅញទៅដល់ទីកន្លែងនោះមានមនុស្សពីរនាក់មកជាមួយផង លោកអ្នកត្រួតត្រាជាវិស (Jarris) ក្រុមស្កត់ឡែន់យ៉ាត” និងមនុស្សម្នាក់ដែលជាអ្នកតំណាងក្រុម “ហូរេញ អុហ្វិស” ។

ក្នុងពេលនោះ លោកសៀរហ្វ៊ែរ បានប្រគល់របស់ដែលគេដែកហូតយកពីខ្ញុំចំពោះមុខលោកទាំងពីរនាក់ ។ រួចលោកមានប្រសាសន៍ទៅកាន់មន្ត្រីទាំងពីរនាក់ថា "ខ្ញុំសូមប្រគល់មនុស្សនេះជូនលោក តែចំណែកខាងក្រសួងអគ្គរាជទូតចិន មានសិទ្ធិទាំងស្រុងយោគយល់ដូចពីដើម" ។ លោកសៀរម៉ាការនិយាយពាក្យក្រៅពីនេះច្រើន តែដោយចិត្តខ្ញុំភ័យញាប់ញ័រជាខ្លាំង ខ្ញុំក៏ពុំបានយកចិត្តទុកដាក់ក្នុងការស្តាប់ប៉ុន្មាន ។

គេបានឲ្យដំណឹងខ្ញុំថា "អ្នកឯងរួចពីទុក្ខទោសហើយ" លោកសៀរម៉ាការ៉ែបានចាប់ដៃគ្រវីនឹងយើងទាំងអស់គ្នា ការគួរសមមានហាក់ដូចជាសណ្ឋានលោកយូដាស (Salut de Judas)[១] ។ រួចគេនាំខ្ញុំចេញទៅក្រៅតាមទ្វារចំហៀងចុះទៅក្រោមដី ហើយមានជណ្តើរឡើងទៅកាន់ទ្វារក្រោយស្ថានអគ្គរាជទូតចិនចេញទៅផ្លូវវ៉ៃមុតហ៍ ។

ឯរឿងដែលគេឲ្យយើងចេញតាមទ្វារក្រោយ ចំណែកពួកម៉ាកខ្ញុំដែលជាជាតិអង់គ្លេសមិនបានដាក់គំនិតពិចារណាត្រង់នេះសោះ ពីព្រោះចិត្តរវល់ត្រេកអរក្នុងការជួយសង្គ្រោះខ្ញុំបានដូចបំណង ។ តែការដែលពិតនោះគឺចិនតាំងដែលនៅស្រុកខនិងមជនបទជាមួយនឹងខ្ញុំ ទីងលោកសៀរ.

១ ស៊ូដាស់:សាវកព្រះយេស៊ូគ្រិស្ត បានចូលដៃនឹងពួកបច្ចាមិត្ត ចាប់ព្រះយេស៊ូយកទៅធ្វើទណ្ឌកម្មឡើងឈើឆ្កាង ។

ហាល្វីដេម៉ាការទី មានចិត្តមើលងាយដល់ពួកជាតិប៉ូតាំ ប្រទេសជាជាងគេ ទាបថោកបំផុត ។ កិច្ចដែលលោកសៀវម៉ាការទីបាននាំមុខកំណាន់ រដ្ឋាភិបាលប្រិតនិក ចេញពីស្ថានអគ្គរដ្ឋទូតបរទេស តាមច្បាប់ក្រោយ ទុកជាលោកនេះប្រមាថមើលងាយពេញទី ដូចជាសាកសួរ ដែលមានបដិកូលគួរខ្ពើមរអើមគន់ពេក ។ បរិយាកាសដែលប្រព្រឹត្តទៅនេះ នាំឲ្យគាប់ចិត្តយ៉ាងខ្លាំងដល់ជាតិអង់គ្លេស ពីព្រោះលោកសៀវម៉ាការទីជាជាតិជាមួយគ្នា ដែលពួកម្ចាស់ស្ថានអគ្គរដ្ឋទូតដែលបានប្រព្រឹត្តបែបនេះ ទុកជាសំដែងអាការមិនគោរព ហើយប្រមាថមើលងាយផង ។ គេបានសំដែងហេតុផលថា បានជាធ្វើយ៉ាងដូច្នេះ ព្រោះក្នុងពេលនោះមានពួកកំណាន់កាសែតជាច្រើន, មានមនុស្សនៅខាងក្រៅគេហដ្ឋានតាមជួលច្រើន ហើយថាក្រុម "ហ្វូរេញ អុហ្វិស" ត្រូវបានចង់ឲ្យរឿងការនោះស្ងប់ស្ងាត់ដោយស្ងាត់កំបាំង ។

កិច្ចការដែលជួយសង្គ្រោះខ្លួនឲ្យរួចពីទោសកំហុស នេះទុកជាឧត្តមគតិខាងនយោបាយអង់គ្លេស ។ តែចំណែកខាងចិន របៀបដែលធ្វើបែបនេះ បើទុកជាសំរេចដូចបំណងក៏គង់ឃើញជាក់ច្បាស់ ថានយោបាយអង់គ្លេសមិនវិសេសវិសាលប៉ុន្មានទេ ។

របស់នោះមិនបានឈប់ខាងក្រុងកដ្ឋការ "ស្កុតឡែនយ៉ាដ" ទេ ក្រឡប់ជាទៅឈប់មុខគោលដ៏យង់ខ្ពង់មួយនៅ "វ៉ៃហល" (White ball)

ហើយយើងក៏ចុះពីរថសេះដើរទៅ ។ ស្រាប់តែពួកអ្នកនិពន្ធកាសែតមក ជួបជុំមិនដឹងជាមកពីទិសតំបន់ណា យើងបានឃើញពួកនេះអម្បាញ់មិញ នៅឯមណ្ឌលប៉ុស្តិ៍ប្រហែលជាចម្ងាយពីនេះទៅ មួយម៉ៃល៍ ហើយ មិនដឹងជាយ៉ាងណា បានជារថសេះដល់ទីនេះ ស្រាប់តែឃើញពួកនេះ មកដល់ទីនេះដែរ មិនមានទោះយល់អ្វី ហាមកុំឲ្យពួកនេះចូលមកជិតបាន មានមនុស្សម្នាក់លបឡើងមកជិះរ៉េះមួយទីងនាយសារថី មកដល់មុខ គោលទីរដ្ឋានក្សេត្រក្រុមការស្កុតឡែងយ៉ាដ ក៏បញ្ឈប់រទេះសេះ នោះ ពីព្រោះបើខ្ញុំចូលទៅដល់ក្រុមការស្កុតឡែងយ៉ាដ មិនមាន អ្នកណាតាមមកយកការបាន នៅទីនោះខ្ញុំឃើញពួកអ្នកចង់ដឹងរឿងការ មកឡោមព័ទ្ធជុំវិញពួកនេះប្រាថ្នាចង់ឃើញខ្លួនខ្ញុំឯងពួកជាតិចិន ដែល ចង់ហុតឈាមស្រស់ខ្ញុំទៅទៀត មានពួកខ្លះកាន់ខ្មៅដៃសរសេរតួពស បែបអក្សរបុរាណជាតិអេស៊ីប ដែលខ្ញុំមិនដែលឃើញស្គាល់ថាគេសរសេរ អក្សរនេះត្រូវបោយភាពច្រើន ដល់ថ្ងៃក្រោយបានខ្ញុំដឹងថាជាជវលេខ វិញ (Sténographie) ។

ខ្ញុំពណ៌នារឿងការបស់ខ្ញុំឲ្យពួកនិពន្ធកាសែតស្តាប់សព្វគ្រប់ ទាល់តែលោកតង់ទ័ថាឈប់ប៉ុណ្ណេះហើយ ។ រួចខ្ញុំក៏ជិះរទេះសេះដំរង់ទៅ ក្រុមស្កុតយ៉ាដ ជាមួយនឹងលោកតង់ទ័ នៅទីនោះខ្ញុំត្រូវគេសាកសួរមួយ ម៉ោងហើយ ក្នុងពេលនោះខ្ញុំបានធ្វើការពណ៌នាពីរឿងដែលគេចាប់ខ្ញុំ

ឈកៈចាំឃុំឃាំង ។ គេបានមើលកាយការខ្ញុំចំពោះមុខមន្ត្រីទៅក្រុមនោះ គេបង្គាប់ឲ្យខ្ញុំចុះហត្ថលេខា ខ្ញុំក៏លាពួកក្រុមនគរបាលត្រឡប់មកវិញ ។ លោកគន់ខ្ញុំឈឺ ខ្ញុំក៏បានមកកាន់គេហដ្ឋានរបស់ខ្លួន ហើយញាតិមិត្តរបស់លោកបានទទួលខ្ញុំដោយសោមនស្សរីករាយពន់ពេក ។ រួចគេបានលៀងភោជនាហារខ្ញុំ ហើយគេបានលើកកែវស្រាចំពោះមុខខ្ញុំហើយក៏ត្រៀវសប្បាយ ។

រឿងការឃុំឃាំងខ្ញុំចប់តែប៉ុណ្ណេះ

---

# មធុរភាសិត

## អារម្ភកថារបស់អ្នករៀបរៀង

បទមាតិកាតាំងពីដើមមានតែក្នុងនិទានមុខនេះ លោកអ្នកទកញ្ញា សុភាសិតប្រៀប ... ជាការពិតនៅតែត្រូវផ្ចង់ផងគាលមិនទាន់ទទួល អធិប្បាយនៅឡើយ តែនរោលព្យាង្គ ដល់បន្តែខ្ញុំបានចាំទុកមក ដល់ក្នុងកាលឥឡូវនេះ ... មានច្បាស់ តែលោកមិនបាន អធិប្បាយក្នុងបទមាតិកា ទាំងនោះឲ្យបានពិស្ដារ ទាំងមិនបានសរសេរគត់ ត្រាទុកដើម្បីឲ្យជនានុជនបានដឹងសេចក្ដីនោះៗ នៅឡើយ ។

ខ្ញុំយល់ថា សុភាសិតនេះជាពាក្យល្អមិនមែនជាពាក្យខុសទាស់ទំនង ពុទ្ធភាសិតឡើយ ហើយជាមេពាក្យល្អឲ្យអ្នកផងចងចាំបានដោយងាយ បើអ្នកណាបានចងចាំហើយ ក៏ជាគតិមួយដែលជាគ្រឿងបំបែរមុខអ្នកនោះ ឲ្យទៅកាន់សោត្ថិភាពបាន ព្រោះហេតុនោះ បានជាខ្ញុំចំរៀបរៀងនិង អធិប្បាយសុភាសិតនេះឲ្យបានពិស្ដារជាលំដាប់ហូរហែទៅ ព្រមទាំង បានស្រង់ពុទ្ធភាសិតពីគម្ពីរផ្សេងៗ មកជាសំអាងខ្លះ ។

ខ្ញុំសូមអរគុណលោកអាចារ្យ ស៊ុំ និងលោកអាចារ្យ ពិន ជាពួក ក្រុមជំនុំប្រែព្រះត្រៃបិដក ដែលបានជួយឈឺឆ្អាលកែសម្រួលសេចក្ដី នេះ សូមសេចក្ដីមេសេចក្ដីកើតមានដល់យើងខ្ញុំទាំងអស់គ្នា និង បណ្ដាជនអ្នកកាន់ព្រះពុទ្ធសាសនា ជាដរាបទៅហោង ។

ព្រះមហា សោម - ឡុច

ល្បែងអ្វីមិនស្មើល្បែងចម្បាំង
កំឡាំងអ្វីមិនស្មើកំឡាំងកម្ម
ផ្ដាំអ្វីមិនស្មើផ្ដាំព្រះរតនត្រ័យ
ភ័យអ្វីមិនស្មើភ័យខ្លាចបាប
លាភអ្វីមិនស្មើលាភឥតរោគបៀតបៀនប្រាណ
ទានអ្វីមិនស្មើទានធម៌ទេសនា
ប្រាជ្ញាអ្វីមិនស្មើប្រាជ្ញាអ្នកបានព្រះអរហត្ត
អត្ថអ្វីមិនស្មើអត្ថបរមត្ថអភិធម្ម ។

អធិប្បាយ

ត្រង់ចំណុចថា "ល្បែងអ្វីមិនស្មើល្បែងចម្បាំង" នោះ សេចក្ដីអធិប្បាយថា ចម្បាំងនោះគេចាត់តាំងពីសត្វជល់គ្នា ឬខាំគ្នា រហូតដល់ពួកមនុស្សឈ្លោះតាំងតែដៃគ្នាមានជេរប្រទេចជាលេងដាក់ទាត់ ឬចាក់កាប់សម្លាប់គ្នាដោយគ្រឿងសស្ត្រាវុធ ខានតែក្ស័យក្ស័យជាដើម សង្គ្រោះចូលក្នុងការចម្បាំងទាំងអស់ ។

ក្នុងលោកនេះគេល្បែងអ្វីឲ្យជាទីរំភើបចិត្តនៃជនទាំងឡាយ ដូចល្បែងចម្បាំងគ្មាន ព្រោះល្បែងទាំងនោះ បើកើតឡើងក្នុងទីណាហើយ អ្នកផងទាំងពួង ប្រែងភ័យតក់ស្លុតរន្ធត់ញាប់ញ័រ ក្នុងវេលាស្គាល់គាពុត

ម្ដាយ ៗ តែងស្គាល់កូន តាំងពីបងប្អូនមិត្រសំឡាញ់ក៏តែងស្គាល់គ្នា ដោយភ័យខ្លាំងពេកនេះបើល្បែងធំ បើល្បែងតូចល្មម មិនបានជាចំណាស់ទេ ដូចសត្វជល់គ្នាឬទាំគ្នាឬតួមនុស្សដែលគ្រាន់តែឈ្លោះតាស់តែងដាល់តប់គ្នាជាដើមនោះ អ្នកផងទាំងពួងច្រើនត្រឡប់ចូលចិត្តចង់មើលវិញ ប្រសិនបើជនទាំងឡាយ កំពុងប្រជុំគ្នាលេង ឬមើលល្បែងផ្សេងៗ មានព្រៀងកំដរដើមក្ដីណាមួយ ហើយមាននរណាឈ្លោះតាស់តែងគ្នាក្ដីនោះ ជនទាំងនោះឯងមុខជានឹងបាក់ពពួនទៅមើលអ្នកឈ្លោះគ្នាសិន អត់ទ្រាំបានមើលមិនបាន សូម្បីតែកូនក្មេងក៏ក៏ចង់មើលដែរ ពុំនោះសោតគេគ្រាន់តែឮកុន[1] ស្រែកបោលលេងរឿងអ្នកឈ្លោះតាស់តែងដាល់តប់គ្នា ឲ្យមហាជនមើលក្ដី ឬគេនិយាយរឿងមានរឿងតមកេរ្ដិ៍ជាដើមក្ដី ជនទាំងឡាយក៏ចូលចិត្តចង់មើលចង់ស្ដាប់ជាបំផុតដែរ នេះហៅថា ល្បែងអ្វីមិនស្មើល្បែងបម្បាំង ៗ

ត្រង់បទថា "កំឡាំងអ្វីមិនស្មើកំឡាំងកម្ម" នោះ សេចក្ដីអធិប្បាយថា កម្ម គឺអំពើដែលបុគ្គលធ្វើ កម្មនេះមានពីរយ៉ាង គឺកំឡាំងកុសលកម្ម ១ អកុសលកម្ម ១ ។ កម្មទាំង ២ នេះមានកំឡាំងដ៏ក្រៃលែងរកអ្វីប្រៀបផ្ទឹមពុំបាន ទាំងឲ្យផលទៀតក៏ផ្សេងគ្នា កុសលកម្មឲ្យផល

---

១ ហៅថា "កល" ត្រូវជា ពាក្យថា "កុន" នេះខ្មែរហៅក្លាយតាមសៀម ព្រោះសៀមអានខ្យល់ "ល" ទៅជាខ្យល់ "ន" ។ (កលទបាយ ឬទបាយកល) ។

ជាសុខ អកុសលកម្មឲ្យផលជាទុក្ខ គឺថាបុគ្គលណាធ្វើកុសលកម្មហើយ ដឹកនាំបុគ្គលនោះឲ្យបានសុខ បុគ្គលណាធ្វើអកុសលកម្មហើយនាំបុគ្គលនោះឲ្យបានទុក្ខ តាមសមគួរដល់អំពើដែលបុគ្គលធ្វើហើយធ្វើ នៅត្រង់សមដូចព្រះពុទ្ធដីកាថា

ន ហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ
អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគតឹ ។

សភាវៈទាំងពីរគឺគុណ ១ ទោស ១ មិនបានឲ្យផលស្មើគ្នាទេ ទោសតែងនាំសត្វទៅកាន់នរក គុណតែងនាំសត្វទៅកាន់សុគតិ ។

បណ្តាកម្មទាំង ២ នេះ បើកម្មណាមួយឲ្យផលដល់បុគ្គលណាហើយ បុគ្គលនោះនឹងប្រែកែកម្មមិនព្រមទទួលយក ក៏ប្រែកែមិនបានត្រូវតែទទួលយកតាមផលកម្មរបស់ខ្លួនរៀងៗ អ្នកធ្វើល្អត្រូវទទួលយកចំណែកល្អ អ្នកធ្វើអាក្រក់ត្រូវទទួលយកចំណែកអាក្រក់ ។ កំឡាំងកាយ កំឡាំងទ្រព្យសម្បត្តិ កំឡាំងឫទ្ធិអំណាច ទាំងកំឡាំងផ្សេងៗដែលពូកែខ្លាំង ក៏មិនស្មើនឹងកំឡាំងកម្មទាំង ២ នេះឡើយ កាលបើកំឡាំងកម្មទាំង ២ នេះ កំឡាំងកម្មណាមួយមកដល់ហើយ កំឡាំងឯទៀតៗ ទាំងប៉ុន្មាន ក៏សាបសូន្យបាត់អស់ ។ កំឡាំងអកុសលកម្មនោះដូចជានិទានព្រះបាទសុប្បពុទ្ធជាឧទាហរណ៍ សូមនាំរឿងនេះមកសំដែងដោយសង្ខេបថា

ព្រះបាទសុប្បពុទ្ធនោះជាស្តេចមានបុណ្យអស្ចារ្យ ហើយត្រូវជាព្រះបិតាក្មេកនៃព្រះពុទ្ធជាម្ចាស់ផង ទ្រង់មានព្រះរាជបុត្រពីរព្រះអង្គគឺៈ ព្រះនាងពិម្ពា ១ ព្រះទេវទត្ត ១ ។

កាលព្រះមហាបុរសទ្រង់លះណាចចាកចោលព្រះនាងពិម្ពាចេញទៅទ្រង់ព្រះផ្នួសបានសម្រេចអនុត្តរសម្មាសម្ពោធិញ្ញាណហើយ ទ្រង់មានព្រះទ័យអាណិតអាសូរទេវទត្តជាប្អូនថ្លៃនោះពន់ពេក ដោយទ្រង់ព្រះតម្រិះយល់ឃើញថា បើទេវទត្តនោះនៅជាគ្រហស្ថ យូរទៅមុខជានឹងប្រព្រឹត្តធ្វើកម្មអាក្រក់ជាទម្ងន់ ហើយនឹងធ្លាក់ទៅរងទុក្ខក្នុងនរកជាយូរអង្វែងឆ្នាំ ប្រសិនបើមកបួសហើយ ទោះបីនឹងធ្វើអំពើអាក្រក់ណាមួយជាទម្ងន់ ក៏មិនធ្ងន់ស្មើនឹងអំពើដែលខ្លួនធ្វើក្នុងភេទជាគ្រហស្ថឡើយ ហេតុនោះហើយបានជាទ្រង់បំបួសទេវទត្តក្នុងព្រះពុទ្ធសាសនា ។

ព្រោះក្រោយមកព្រះបាទសុប្បពុទ្ធទ្រង់ព្រះពិរោធខ្លាំងថា "សមណគោតមដាក់ចោលកូនស្រីរបស់អញទៅបួសហើយ ម្តេចឡើយក៏មកសសោះអន្ទងយកទេវទត្តកូនអញទៅបំបួសទៀត" ទ្រង់ចងគំនុំនឹងព្រះសាស្តាដោយហេតុ ២ ប្រការនេះឯង ។

វេលានោះព្រះសម្ពុទ្ធជាម្ចាស់ជ្រាបហេតុនោះច្បាស់ ក៏ទ្រង់មានព្រះទ័យអាណិតអាសូរស្តេចនោះពន់ពេក ទើបព្រះអង្គព្រមទាំងភិក្ខុសង្ឃជាបរិវារស្តេចទៅទ្រង់បិណ្ឌបាតក្រោស ឯស្តេចនោះក៏ឥតមានព្រះទ័យ

ជ្រះថ្លាសោះ នាំឲ្យរឹងរឹតតែមានសង្ខ្យាំងច្រើន ហើយទ្រង់សោយ
សុរាបានស្រវឹងថ្លល់ លុះព្រះពុទ្ធជាម្ចាស់ស្តេចទៅដល់ ព្រះបាទសុប្បពុទ្ធ
ក្រាស់ចង្អៀតឲ្យរាជបុរសឃាត់មិនឲ្យព្រះអង្គស្តេចយាងទៅបាន សម្តេច
ព្រះអនាវរណញ្ញាណកេតុកាសទឹងចូលទៅពុំបាន ក៏ទ្រង់ត្រឡប់មកវិញ ៗ
លំដាប់ពីនោះមក ព្រះបាទសុប្បពុទ្ធបាន ចាត់រាជបុរសម្នាក់ថាឯងត្រូវទៅ
តាមសមណគោតម លបចាំស្តាប់ការណ៍មើល បើព្រះសមណគោតម
ដំណាលរឿងរ៉ាវពីអញដូចម្តេច ត្រូវឯងត្រឡប់មកប្រាប់អញវិញ
យ៉ាងឆាប់ ៗ ឯរាជបុរសនោះក៏ទទួលព្រះរាជឧង្ការក្រាបបង្គំលាចេញ
ទៅតាមព្រះពុទ្ធជាម្ចាស់ទៅទាន់នាកណ្តាលផ្លូវ ៗ វេលានោះព្រះទស-
ពលញ្ញាណទ្រង់ញញឹម ៗ ព្រះអានន្ទក៏ក្រាបបង្គំទូលសួរថា ហេតុអ្វី
បានជាព្រះអង្គទ្រង់ញញឹម ៗ ព្រះសត្ថុតបថា អានន្ទបានជាតថាគត
ញញឹម ព្រោះតថាគតដឹងថានៅតែ ៧ ថ្ងៃទៀត ព្រះបាទសុប្បពុទ្ធនេះ
នឹងលិចចុះក្នុងផែនដី ( ព្រះធរណីស្រូប ) ក្បែរជណ្តើរប្រាសាទពុំខាន
ឡើយ ៗ ឯរាជបុរសដែលទៅលបស្តាប់ការណ៍នោះ បានឮច្បាស់
ហើយក៏ត្រឡប់ទៅក្រាបបង្គំទូលព្រះបាទសុប្បពុទ្ធតាមរឿងនោះដោយ
សព្វគ្រប់ ស្តេចនោះហេតុតែប្រកាន់ដោយមានះប្រាថ្នាចង់ឈ្នះ ក៏ទ្រង់
ព្រះចិន្តាថា បើសមណគោតមថាយ៉ាងនេះខ្ញុំត្រូវ អញនឹងផ្ចាញ់ផ្ចាល់
ឲ្យខ្មាសគេពុំខាន ហើយក៏ទ្រង់ឲ្យរាជបុរសទាំងឡាយជញ្ជូនគ្រឿង

ឲបុរោហិតតាមស្តេចហោះទៅលើប្រាសាទ ៧ ជាន់ ហើយទ្រង់ឲ្យគេមនុស្សខ្លាំងពូកែជាច់ឲ្យនៅចាំទ្វារទាំង ៧ ជាន់ក្នុងទ្វារមួយៗ មានមនុស្សពីរនាក់ៗ ហើយឲ្យបិទទ្វារទាំងនោះខ្ជាប់មិនឲ្យអ្នកណាចូលចេញបានហើយទ្រង់ផ្តាំថា អ្នកពល់គ្នាប្រុងចាំមើល បើដល់ថ្ងៃទី ៧ ហើយឃើញអញចុះពីលើប្រាសាទមក ត្រូវនាំគ្នាចាប់អញលើកដាក់ទៅលើប្រាសាទវិញកុំបីប្រហែសឡើយ លុះផ្តាំស្រេចហើយស្តេចក៏គង់ក្នុងល្វែងប្រាសាទជាន់លើបំផុតជាសុខសប្បាយ ។

វេលានោះ ព្រះសព្វញ្ញុពុទ្ធបានជ្រាបហេតុនោះហើយ ទើបទ្រង់ត្រាស់ទៅនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទសុប្បពុទ្ធនោះកុំថាត្រឹមតែនៅលើប្រាសាទ ៧ ជាន់ ទុកជាហោះទៅលើវេហាស៍ក្តី លើអាកាសក្តី ឬចូលទៅនៅក្នុងមហាសមុទ្រក្តី ចូលទៅនៅក្នុងរូងភ្នំក្តី ក៏គង់មិនរួចអំពីបាបកម្មឡើយ ធម្មតាពាក្យព្រះពុទ្ធទាំងឡាយមិនដែលខានពីរទេ មានតែ ១ តែជាយ៉ាងណាពិតយ៉ាងនោះ ព្រះបាទសុប្បពុទ្ធនោះមុខជានឹងលិចចុះទៅក្នុងផែនដី ដូចពាក្យតថាគតពោលមិនខុសឡើយ ទើបទ្រង់សំដែងព្រះគាថាថា :

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្វតានំ វិវរំ បវិស្ស

ន វិជ្ជតេ សោ ជគតិប្បទេសោ

យត្រ ឋិតំ នប្បសហេយ្យ មច្ចុ ។

បុគ្គលធ្វើបាបកម្មហើយ ទោះហោះទៅនៅលើអាកាសក៏មិនរួចពីបាបកម្ម ជិះសំពៅទៅនៅក្នុងសមុទ្រ ក៏មិនរួចពីបាបកម្ម ចូលទៅនៅក្នុងរូងភ្នំ ក៏មិនរួចពីបាបកម្ម បុគ្គលដែលស្ថិតនៅក្នុងប្រទេសលើផែនដីហើយមច្ចុគប្បៀតបៀនមិនបាននោះមិនដែលមានទេ ។

លុះដល់ថ្ងៃទី ៧ សេះមង្គលសម្រាប់ក្សត្រស្រែកតម្រៀបជោក ត្រាសផញ្ញាំងក្នុងការទៀង ព្រះបាទសុប្បពុទ្ធបានឮសំឡេងនោះហើយ ក៏មានព្រះទ័យចង់ចុះមកទតសេះ ទើបទ្រង់យាងក្រោកឆ្ពោះទៅត្រង់ទ្វារ ឯទ្វារទាំងនោះក៏បើកឯង មិនបាច់ចាំអ្នកណាបើកឲ្យឡើយ ពួកអ្នកចាំទ្វារនាងលើឃើញហើយ ក៏នាំគ្នាចាប់ស្ដេចនោះចំណងទីទៃដាក់ទៅលើ ចង់ចាប់ដាក់ទៅលើគ្រឡប់ទៅជាចាប់បោះចំលាក់ទៅក្រោមវិញ អ្នកក្រោមចាប់ព្រះបាទទៅក្រោមគេ គ្នាផ្ទាក់ដល់ជើងជណ្ដើរនាងក្រោមជាបំផុត មហាប្រឹថពីក៏ញាក់ញ័រ ប្រេះបែកញែកចេញជាពីរ ស្ដេចនោះក៏លិចចុះទៅក្នុងព្រះធរណីក្បែរព្រះជេតពន វេលានោះ ក៏ធ្លាក់ទៅក្នុងនរកអវិចី ត្រូវទោសដល់មកសព្វថ្ងៃនេះពុំមានរួចឡើយ ។ នេះហើយហៅថាកម្មមិនកុសលកម្ម នេកំទ្បាំងគួរស្ញើ

កុំបាន គួរយើងគប់ប្រាណ ខ្លាចបាបឲ្យដូចស្លាបមាន់ត្រូវរងើកភ្លើង មិនត្រូវមើលងាយបាបឡើយ ។

អានិសង្សនៃកុសលកម្មវិញ ដូចមាននិទាននាយមាលាការ (ជាងក្រងផ្កា) ជាដើម ដំណើររឿងនោះមានសំដែងដោយសង្ខេបថា នាយមាលាការនោះតែងក្រងផ្កាថ្វាយព្រះបាទពិម្ពិសាររាល់ៗថ្ងៃ មិនដែលដាច់ថ្ងៃមួយ ដូនជាបានជួបនឹងព្រះពុទ្ធជាម្ចាស់ក៏មានចិត្តជ្រះថ្លាពេកណាស់ ស្ទើរតែមិនគិតខ្លាចក្រែងស្ដេចទាល់ឡើយ ហើយក៏យកផ្កានោះទៅបូជាព្រះពុទ្ធជាម្ចាស់ ភរិយារបស់នាយមាលាការនោះ ដឹងរឿងច្បាស់ក៏កើតទោមនស្សអាក់អន់ចិត្ត ទើបនាំនោះទៅក្រាបបង្គំទូលព្រះរាជាគ្រប់ដំណើរនោះដោយសព្វគ្រប់ ដើម្បីឲ្យធ្វើទោសស្វាមីនោះ ។ ព្រះរាជាមិនបានធ្វើទោសនាយមាលាការ ត្រឡប់ជាប្រទានទ្រព្យសម្បត្តិវិញ ។ នេះមកពីកម្លាំងកុសលកម្មរបស់នាយមាលាការដែលមានចិត្តជ្រះថ្លាបានថ្វាយផ្កាដល់ព្រះពុទ្ធឲ្យផលជាទិដ្ឋធម្មវេទនីយសុខទាន់ចិត្ត ។ គួរយើងយកចិត្តទុកដាក់កសាងកុសលឲ្យរឿយៗ កុំបីប្រហែសធ្វេសឡើយ នេះហៅថាកម្លាំងអ្វីមិនស្មើកម្លាំងកម្ម ។

ត្រង់ពាក្យថា ថ្នាំអ្វីមិនស្មើថ្នាំ ព្រោះតែនៅក្រោយនោះមានសេចក្ដីអធិប្បាយថា ថ្នាំពេទ្យក្នុងលោកនេះ មានកម្លាំងពូកែវិសេសណាស់ដែរ ប៉ុន្តែយកមកព្យាបាលរោគរបស់មនុស្ស ជួនកាលបានសះជា ជួនកាលមិន

បានសះជាទេ ឬដឹងយកមកកែហេតុគឺជាតិ ជរា ព្យាធិ មរណៈក៏កែមិន
បានឬកែមនុស្សដែលទីទ័លក្រឲ្យទៅជាមនុស្សមានទ្រព្យសម្បត្តិ កែ
មនុស្សមិនមានយសសក្តិឲ្យបានទៅជាមនុស្សមានយសសក្តិ កែមនុស្ស
វិលវូចប្រព្រឹត្តធ្វើអំពើអាក្រក់មានលួចប្លន់កាប់សម្លាប់ ឬប្រព្រឹត្តលេង
ល្បែងផ្សេងៗ មានបៀរប៉ោជាដើម ឲ្យទៅជាមនុស្សល្អវិញក្តី ក៏កែមិន
បាន បើទុំប្រព្រឹត្តយកថ្នាំពេទ្យទាំងនោះមកកែហើយ ហេតុនោះរឹតរឹត
តែវិវេតខ្លាំងឡើងទៀត ។

បើជនណាប្រាថ្នាចង់ឲ្យហេតុគឺមាន ជាតិ ជរា ព្យាធិ មរណៈ ជា
ដើមឲ្យសះជាបេញបានត្រូវយកថ្នាំ ៣ មុខវិញគឺៈ ព្រះពុទ្ធ ១ ព្រះធម៌ ១
ព្រះសង្ឃ ១ ដែលលោកទុកជាជាឱសថយាទិវិសេស មកទទួលទាន
ដោយគោរពប្រណិបត្តិបូជាករលោបុះ ទើបហេតុទាំងនោះនឹង
សះជាបានគឺថាថ្នាំទាំង ៣ មុខនេះនាបតែហេតុគឺអកុសលចិត្តដែលដឹកនាំ
បុគ្គលឲ្យធ្វើអំពើអាក្រក់ផ្សេងៗមានសម្លាប់លួចប្លន់គេ ប្រព្រឹត្តកាមេ-
សុមិច្ឆាចារ និយាយកុហក ផឹកស្រាមេរ័យជាដើមឲ្យសះជាបាន ។ មិន
តែប៉ុណ្ណោះឱសថទាំង ៣ នេះមានគុណានុភាពអាចជួយស្រោចស្រង់ផ្សះ
ពួកមនុស្សដែលទីទ័លក្រលំបាកឲ្យបានទៅជាមនុស្សមានទ្រព្យសម្បត្តិ
កប់សែនលានគេ [illegible] ឲ្យបានទៅជាស្តេច [illegible] ត្រូវផ្សៀងផ្សកបផល់

បច្ចិមជាតិ នឹងជួយឲ្យបានដល់ព្រះនិព្វានជាស្ថានបរមសុខសិនបានជួបប្រាថ្នា សមដូចពុទ្ធភាសិតថា:

យេ កេចិ ឱសធា លោកេ វិជ្ជន្តិ វិវិធា ពហូ
ធម្មោសធំ សមំ នត្ថិ ឯតំ បិវថ ភិក្ខវេ
ធម្មោសធំ បិវិត្វាន អជរា មរណា សិយុំ
ភាវយិត្វា បបយិត្វា និព្វុតា ឧបធិក្ខយេតិ ។

ឱសថទាំងឡាយឯណា មានច្រើនប្រការក្នុងលោក ក៏មិនស្មើនឹងឱសថគឺធម៌ឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរផឹកនូវឱសថគឺធម៌នោះចុះ លុះអ្នកទាំងឡាយបានផឹកពោលគឺបានចំរើនបានដក់ល់ទុកនូវឱសថគឺធម៌ហើយ ទើបជាអ្នកព្រាត់ទុក្ខ (នៅជាសុខ) ក្នុងព្រះនិព្វានគ្មានជរា គ្មានមរណៈមកបៀតបៀនបានឡើយ ព្រោះហេតុនោះគួរតែយើងទាំងឡាយខំផឹកឱសថគឺធម៌នេះរាល់វេលាចុះ ទើបសះជារោគទាំងពួងបាន នេះហើយហៅថា ថ្នាំអ្វីមិនស្មើថ្នាំព្រះរតនត្រ័យ ។

ត្រង់បទថា **ភ័យអ្វីមិនស្មើភ័យខ្លាចបាប** នោះសេចក្ដីអធិប្បាយថា ភ័យទាំងសព្វទៀតៗ មានខ្លាដំរីជាដើមមិនហៅថាជាភ័យចំពោះឡើយ ព្រោះថាសព្វទាំងនេះបើនឹងមកបៀតបៀនហើយ យើងគិតគេចខ្លួនរត់ចេញទៅត្រង់ទីនេះទីនោះ ក៏គង់នឹងបានរួចខ្លះ ២

ក៏យកចិត្តបាបនេះពិចារណាទីងវែងគេបជាបំផុត មិនដឹងជាវែងវែងគេបទៅជ្រៅ ពួកគ្រន់ទីណាឲ្យកំបាំងពីបាបបាន ព្រោះបាបនេះគ្មានរូបមានតែឈ្មោះ ព្រោះហេតុនោះបានជាបបួលបាំងឲ្យយកនំហោកគម្រងខិនវែងគេបរូប ៗ មួយទៀតបើជនណាធ្វើបាបតិចក្ដីច្រើនក្ដី ចំពោះមុខគេក្ដី កំបាំងមុខគេក្ដី កុំឲ្យគិតថាមិនអីទេ ៗ អញធ្វើបន្តិចបន្តួចទេ គ្មានអ្នកណាឃើញឬដឹងឮផង ទេអ្នកណាធ្វើបាបហើយគិតយ៉ាងនេះ ហៅថាមើលងាយបាប ឯចុងចប់ នេះគោះបើបុគ្គលធ្វើតិចក្ដីច្រើនក្ដី កាលបើដល់ពេលហើយ ទៀតគេឲ្យ ផលពុំខាន ប្រៀបដូចផ្កាដើមឈើទាំងពួង កាលបើមិនទាន់ដល់រដូវ ក៏មិនទាន់បញ្ចេញផ្កាផ្លែមកឡើយ លុះវេលាដែលដល់រដូវហើយ ទើបបញ្ចេញផ្កាផ្លែឲ្យជាក់ស្ដែងហាក់ណាមិញ កាលបុគ្គលកំពុងធ្វើបាប ក៏មិនទាន់ឃើញរូបបាបនៅឡើយទេ លុះដល់វេលាឲ្យផលជាគុណទោសមក ដល់ ទើបបានដឹងខ្លួនក៏យ៉ាងនោះដែរ មានតំណាលដូចព្រះថេរមួយអង្គ ឈ្មោះសោសុរតិស្ស (ព្រះតិស្សត្រៀមក្រម) ទ្រង់នាំរឿងនោះមកសំដែងដោយសង្ខេបថា :

ក្នុងកាលខន្ធនីវេរកើយ មានព្រះថេរណា ស្រុកមួយអង្គមិនគ្ង មកពីទីឆ្ងាយមកស្នាក់នៅវត្ត ១ ឯលោកម្ចាស់ធិការនោះក៏ព្រមឲ្យស្នាក់ នៅ ៗ លុះនៅយូរបន្តិចទៅ ឧបាសកម្នាក់ដែលបម្រើវត្តនោះមានសេចក្ដី ជ្រះថ្លាបានថ្វាយព្រះថេរ ស្រុកព្រៃផ្សេងៗ ...

ផ្ទះរបស់ខ្លួនរៀងរាល់ថ្ងៃ ៗ លុះដល់ថ្ងៃត្រង់ហើយ ចៅអធិការមាន សេចក្តីប្រណីណាស់ មិនចង់ឲ្យព្រះវិញ្ញាណស្រេកទាះទៅក្នុងវត្តហេតុគិតថា ណេះ ខនេះបើនៅផ្ទះហេតុខ្លួនជាឧបាសកណេះប្រគេនញ៉ាំពប់អាហារជានិច្ច ហើយក៏គិតគេរៀងជាណ្ដាញព្រះវិញ្ញាណស្រកាមោះបញ្ជូនវត្ត ៗ លុះដល់ ព្រឹកស្អែកឡើងចៅអធិការយកចាហួយពាសទ្វារ ដើម្បីមិនឲ្យព្រះវិញ្ញាណ- ស្រកចេញមកខាងក្រៅបាន ហើយទៅទទួលកក្កុងស្រុកតៃម្នាក់ឯង ៗ ឯឧបាសកនោះកាលបើមិនឃើញព្រះវិញ្ញាណស្រកមកជាមួយផង ក៏សួរ ថា បពិត្រលោកម្ចាស់ ចុះហេតុដូចម្តេចបានជាមិនឃើញលោកអាគន្ទុកៈ និមន្តមកផង ៗ ចៅអធិការតបថា ចាំមើលលោកនោះដេកលក់ស្រមុក ណាស់ដាស់មិនភ្ញាក់ទេ អាត្មាចាំយូរពេក បានជាមកតែម្នាក់ឯង ៗ ឧបាសកនោះស្រៀមមិនជាដូចម្តេចទៀតឡើយ លុះចាក់បែងកត្ត ប្រគេនចៅអធិការស្រេចហើយ ទើបនិយាយថា ខ្ញុំករុណាសូមផ្ញើ បង្ហាន់ទៅប្រគេនលោកអាគន្ទុកនោះផងបានឬទេ ៗ ចាំអើនពាបាន ហើយ ក៏នាំបង្ហាន់បញ្ញើនោះទៅដល់ពាក់កណ្ដាលផ្លូវ ក៏គិតថា លោកអាគន្ទុក នោះ ពេលព្រឹកបានបាយស៊ីកល់ថ្ងៃហើយ មុខជាមិនអាចនឹងដើរចេញ ពីវត្តអញទេ បើដូច្នេះ គួរតែអញកុំយកទៅឲ្យឡើយ អញនឹងចាក់បាយ សម្ល់នេះចោលឲ្យអស់ តែបើអញចាក់ចោលក្នុងព្រៃឬក្នុងផ្លូវនេះ ក្រែង ជួនជាមានគេដើរមកឃើញនាំឲ្យអន្តរាយដល់ខ្លួន ហើយចុះអញនឹងដើរ

មើលទៅខាងមុខទៀត លុះដើរទៅៗ ទៅជួបព្រៃខ្ទឹងធំពងក្ងានដែល គេដុតបំពក់ភ្លើងស្រែ ហើយក៏កកាយរើសពងក្ងានឆ្អិនបាយសម្ភុកទាំងក្រអើក ក្ងានឆ្អិនផុតមានសេសសល់ឡើយ ហើយក៏ដើរចូលទៅក្នុងព្រៃ ។

ឯលោកអានន្ទក៏ស្តាប់គាថា ព្រះពុទ្ធនោះឯង ។ ចំណែកខាងនិទានបុព្វ-ហេតុរឿងក៏ផុតបំណងរឿងនោះសោះ ព្រោះធ្លាប់ខុសបិតុ ហេតុអំការមួយៗ ដែលមានបត្តទៀងត្រង់លក្ខណៈស ចំណេះជាមានតំបន់រូបភាពក្រាក់ថែបនេះសោះ ឯហេតុផលការនោះលុះហើយនៅកាលអស់ជីវិតក៏ស្លាប់ទៅ-កាលទៅ ។ កើតក្នុងនរកនិងទុក្ខវេទនា ដោយអស់ឆ្នាំ ក្រោយមកទៀតមក បានមកកើតក្នុងត្រកូលអ្នកមានទ្រព្យសម្បត្តិច្រើន ។ ចាប់ដើមតាំងពីកូននោះមកចាប់ផ្ទៃ ដល់ថ្ងៃប្រសូត មាតាបិតាក៏ធ្លាក់ខ្លួនទៅជាអ្នកក្រីក្រលំបាកវេទនាយ៉ាងខ្លាំង លុះកូននោះធំល្មមដើរបានវេលាណា មាតាបិតាក៏លះលែងកប់អាចបណ្តេញចេញពីផ្ទះ ដោយគិតឃើញថា កូននេះជាកូនកាឡកណ្ណីធ្វើឲ្យទៅយូរទៅក៏ក្រ ។ ឯទារកនោះក៏រងទុក្ខវេទនាក្រៃពេក តែងដើរសូមពាសវាលល់ថ្ងៃ ក៏គ្មានអ្នកណាឲ្យធានបន្តិចបន្តួចសោះ ម៉ោះក៏ដើរជ្រកមករើសគ្រាប់ឆ្នាយ ១ គ្រាប់ ២ គ្រាប់ក្រោមផ្ទះគេចិញ្ចឹមជីវិតមុខខ្លួនឲ្យវេទនាពេក ។ នេះមិនមកពីហេតុអ្វីផ្សេងតែពីអំពើអាក្រក់ដែលខ្លួនធ្វើពីជាតិមុន គឺការពិលាសការប្រយោជន៍គេរបស់ណាគេត្រូវបាន ខ្លួនធ្វើមិនឲ្យគេបាន ច្រើនពួកឃោរបស់គេនោះមក

ធ្វើជាទោសខ្លួនវិញ ធ្វើបាបណា ៗ ផលអកុសលនឹងផ្តល់មកវិញក៏យ៉ាងនោះ ៗ មិនឲ្យលើសគ្នាឡើយ ៗ ព្រោះហេតុនោះហើយ គួរយើងវៀរលែងអំពើអាក្រក់ចេញ កុំគេរៀនរកហេតុពាគេ កុំកាប់សម្លាប់ឬកុំចងគំនុំព្យាបាទបំផ្លិចបំផ្លាញគេ បើមិនបានឲ្យវត្ថុ ឬមិនបានបីបាច់ថែទាំទំនុកបំរុងគេទេ កុំទៅជ្រុះឲ្យគេក្តៅក្រហាយឡើយ កុំយកសុខតែម្នាក់ឯង ហើយឲ្យទុក្ខទៅគេ កុំលោភចង់បានចង់មានតែម្នាក់ឯងពេក ត្រូវមើលនាយមើលអាយ ក្រែងនានា ព្រោះធ្លាក់អត្តពយប៉ះមកដល់ខ្លួន ក្នុងលោកនេះនិងលោកខាងមុខ ៗ

លុះគ្រាក្រោយមកព្រះរាជបុត្រនិមន្តទៅបិណ្ឌបាតបានឃើញទារកនោះហើយ ក៏មានព្រះទ័យករុណាអាសូរនាំយកទៅនៅវត្តបង្ហាត់បង្រៀនអក្សរបានចេះដឹងគួរសមគ្រាន់បើ លុះធំឡើងឲ្យបួសជាសាមណេរ ៗ តាំងពីបួសឡើងកាលណាមិនដែលបានអាហារពេញឆ្អែតពោះម្តងសោះ ដរាបដល់អាយុ ២០ ឆ្នាំឲ្យបំពេញឧបសម្បទាជាភិក្ខុទៀត ក៏នៅតែលំបាកវេទនា បើទៅបិណ្ឌបាតក្នុងណា ឥតមានអ្នកណាមួយយកបង្ហាន់មកដាក់បាត្រឡើយ ម៉្លោះហើយក៏កើតទុក្ខមុខក្រៀមក្រំ ដោយហេតុនោះបានជាគេសន្មតហៅថា លោសកតិស្ស ព្រះតិស្សៈក្រៀមក្រំ ៗ

(មានត)

## អំពីពិធីបុណ្យទក្ខិណានុប្បទាន

## ព្រះសពសម្ដេចព្រះមហាសុមេធាធិបតីសង្ឃរាជ

## ព្រះនាម ប្រាក់-ហ៊ិន

ដោយសង្ខេប

---

តាំងតាំងពីថ្ងៃសុក្រ ៩ កើតខែពិសាខ ឆ្នាំកុរ ត្រីស័ក ព.ស. ២៤៩០ ២១ វិច្ឆ ម.ស. ១៨៦៩ ត្រូវនឹងថ្ងៃសៅរ៍ ១០ ខែវៃសាខ ត្រូវនឹងថ្ងៃ (៣ មេសា-១៩៤៨) ត្រូវជា ១ ឆ្នាំ ៤ ថ្ងៃ មានព្រះសង្ឃថេរាចារ្យ សំដែងធម្មទេសនា តម្រិតតាមដោយនានាសូត្រ យ៉ាងពីរោះក្បោះក្បាយ ទើតតាំងពីពេលព្រឹក ចំនួន ១៦៩ អង្គ មានព្រះរាជព្រះគុណព្រះមហាសុមេធាធិបតី ជ-ណាត, សង្ឃនាយក សម្ដេចព្រះធម្មលិខិតធម្មត្ថេរប្រឹក្សា ល្វី.ឯម, និងព្រះពោធិវង្ស ហួត.តាត, ជាដើម ។ មានពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថ ចុះនាំខ្លួនចំណេញល្មម អំពីវិសាខនុវិសាគនៈធម្មជាតិ និងអុលបុណ្យ កាន់សទ្ធាសាទរៈដើម្បីស្ដាប់ព្រះសទ្ធម្មទេសនា ត្រៀបត្រាមរតែរយៈពេលនាក់ព្រឹក គ្រាជាទីជ្រះថ្លាយ៉ាងក្រៃលែង, ហើយបានបរិច្ចាគបច្ច័យគិលានប្រេងភេសជ្ជៈ រៀងៗខ្លួន ប្រគេនធម្មទេសនា រួបរួមតាំងអំពីទនតែមុនព្រះបុណ្យរាប់ពីរ៉ោជ ប្រាំបួនរៀលខ្លួត (២៩២១៩៣,៦២) ។

ក្រុមពុទ្ធបរិស័ទអ្នកស្រុកជាគ្រួសារ សមាជាមួយគ្នា បានចាត់ចែងទក្ខិណានុប្បទាន វេរប្រគេនព្រះសង្ឃឆាន់ចង្ហាន់រាល់ថ្ងៃ ឧទ្ទិសផលថ្វាយដល់វិញ្ញាណក្ខន្ធសម្តេច ចំនួន ១២៧ ក្រុម មានក្រុមលោកស្រីខ្សៀង-តាង៍ ជាភរិយាសម្តេចព្រះអគ្គកែវ-ជួន, ក្រុមលោកឃុនកេសរ-បុប្ផា តាត ព្រមទាំងមាតាបិតា និងក្រុមអ្នកស្រីស្បូ-ចុំ, អ្នកស្រី ស្បូ-សុខុម នាងស្បូ-សាន្តជាដើម ។

ព្រះសង្ឃដែលចំរើនព្រះបរិត្តរាល់ព្រឹកនិងចង្ហាន់ត្រង់រាល់ថ្ងៃ ចំនួនទាំងអស់ ៨០៤៤៤ អង្គ, បច្ច័យដែលចាត់ចែងប្រគេនជាថ្លៃយានជំនិះព្រះសង្ឃទាំងនោះខ្ទះចំនួនពីរពាន់ប្រាំមួយរយហាសិបបួនរៀល (២៦៥៤៛,) ។

អ្នកបំពេញគុណដល់ព្រះសង្ឃ ដែលស្តែងព្រះធម៌ថ្វាយសពសម្តេច រាល់យប់ ចំនួន ៨៦០ អង្គ មានលោកគាញ់ហួន ជម និងអ្នកស្រីគីង៍ជាភរិយាជាដើម ឯបច្ច័យដែលប្រគេនព្រះសង្ឃទាំងនោះចំនួនបួនពាន់ប្រាំបួនរយម្ភៃរៀល (៤៩២០៛,) ។

ក្រុមពុទ្ធបរិស័ទ, កងកម្មករប៉ូលីសកងសាំងស៊ីន មានសេចក្តីជ្រះថ្លាចំពោះគុណសម្បត្តិសម្តេចជាម្ចាស់ បានរៀបរួមគ្នាជាពួកជាក្រុមធ្វើពិធីបុណ្យ បង្សុកូល ឧទ្ទិសកុសលថ្វាយសម្តេចរាល់ទិវាកព្រឹកភ្លឺគាក់ទាន ចំនួនជា ៤២ ក្រុម មានក្រុមញាតិសាលោហិតសម្តេច ក្រុមសិស្ស

សាលាបាឡីជាន់ខ្ពស់ ក្រុមសិស្សសាលាបាលីរងវត្តសាករ៉ែន និងគណៈសង្ឃវត្តសាករ៉ែនជាដើម ។

នៅវេលាយប់ថ្ងៃ អង្គារ ១៤ កើតខែមាឃ (៩ មីនា-៤៨) មានធ្វើពិធីសម្ពោធឆ្លងបុណ្យព្រះសាសនូបត្ថម្ភ ប្រគេនវត្ថុដោយពារស្វាគដល់ព្រះសង្ឃ ៦២១ អង្គ ទាំងគ្រឿងសិក្ខូបករណ៍ផ្សេងៗដល់សិស្សសាលាបាលីរងវត្តសាករ៉ែន, បាននិមន្តព្រះសង្ឃគ្រប់ចំនួន ៣៥ អង្គចំរើនព្រះបរិត្ត និមន្តធម្មកថិកពីររូបប្រកាសធម៌ទេសនាបុច្ឆា-វិស្សជ្ជនា រួចនិមន្តព្រះសង្ឃទាំង ២២១ អង្គបង្សុកូល ព្រមទាំងអង្គាសចង្ហាន់ប្រគេនព្រះសង្ឃចំនួន ១២០ អង្គជាឡារិក ដើម្បីឧទ្ទិសចំណែកកុសលប្រគេនសម្តេច ។ រួមព្រះសង្ឃដែលបង្សុកូលទាំងអស់ចំនួន ៨០៤៧ អង្គ ឯបច្ច័យប្រគេនព្រះសង្ឃទាំងនុះចំនួន ១៧៦៣០៛,០០ ។ រួមបច្ច័យដែលពុទ្ធបរិស័ទចូលបុណ្យជំគាល់សពសម្តេចដាក់ក្នុងឃ្លាំងសង្ឃចំនួន ប្រាំម៉ឺនប្រាំពីររយប៉ែតសិបបីរៀលដប់បីសេន (៥០៧៨៣៛, ១៣ សេន) និងចូលបុណ្យសាងមេរុតាមផ្នែកផ្ការចំនួនមួយសែនប្រាំមួយម៉ឺនប្លាយ . . . ។

របៀបបុណ្យដែលស្រុះស្រួលមិត្រគ្នាមានសភាពបែបនេះគួរទុកជាទិដ្ឋានុគតិដែលពុទ្ធសាសនិកជនទូទៅ ។

# ក្រុមពុទ្ធបរិស័ទខ្មែរជាតិដែនកូសាំងស៊ីន

បានធ្វើបង្សុកូលឧទ្ទិសផលចំពោះព្រះសព សម្ដេច ប្រាក់ - ហ៊ិន

ភទីព្រន្ធប៊ី ។

កាលពីថ្ងៃ ៧ ឧសភា, គ. ស. ១៩៦៨ ម៉ោង ១៧ លោកគ្រូ ថាច់ - សុខ ជាអនុគណវត្តកំពង់ក្រោម, លោកគ្រូឡឹម - អិត ចៅអធិការវត្តចំប៉ា ព្រមទាំងព្រះសង្ឃដទៃទៀត ដែលនិមន្តមកពី ៥៧ វត្ត ក្នុងខេត្តឃ្លាំង (កូសាំងស៊ីន) បាននិមន្តនិងគ្នា និមន្តព្រះសង្ឃគណៈមហានិកាយនិងធម្មយុត្តិកនិកាយចំនួន ២០០ អង្គ បង្សុកូលនៅវត្តភាគកែវតេជោ ដើម្បីឧទ្ទិសផលចំពោះវិញ្ញាណក្ខន្ធនៃអតីតសម្ដេចព្រះសង្ឃនាយក ប្រាក់ - ហ៊ិន ។

នៅទីបំផុតនៃពិធីសត្តប្បករណកិច្ចនេះ លោកគ្រូ ថាច់ - សុខ ក៏ថ្លែងបត្តិទានជាក្នុងនាមនៃពុទ្ធបរិស័ទខ្មែរ ប្រទេសកូសាំងស៊ីនទាំងមូល មុនដំបូងឧទ្ទិសកុសលដល់ព្រះសព សម្ដេចព្រះសង្ឃនាយក បន្ទាប់មកលោកបានថ្លែងយ៉ាងក្រោះក្រាយថ្វាយព្រះរាជកុសលចំពោះព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ដើម្បីឲ្យព្រះអង្គបានប្រកបដោយសេចក្ដីសុខក្នុងសិរីរាជសម្បត្តិជាអង្វែងតទៅហោង ។

## កម្មវិធីបុណ្យឈាបនកិច្ច
## ព្រះសពសម្ដេច

---

### ថ្ងៃ ទី ១ គឺថ្ងៃសុក្រ ២ រោច ខែផល្គុន
### ២៦ ខែមីនា ឆ្នាំ ១៩៤៨

ម៉ោង ១៤ ប្រជុំព្រះសង្ឃរាជាគណៈ ហោរាព្រាហ្មណ៍ - ឧបាសក ឧបាសិកា ព្រមទាំងមន្ត្រីរាជការ រៀបហែក្បួនសពដំកល់លើរថយន្ត ។

ម៉ោង ១៦ ក្បួនហែចេញពីវត្តណាកវ័នគរជ័យ ទៅតាមផ្លូវប៉ូលបែរ តែមេក្រង់ បូឡឺវ៉ាដូដាំឌុឡាក្រេ, លុះដល់ស្ពានកូនចាក់ ទាំងព្រះសង្ឃចំនួន ១០០ រូប រង់ចាំបង្សុកូល, ឡើងសុីសុវត្ថិ កេសុត្តាវង្ស កេសុីសុវត្ថិ ប៉ារី ប៉ូលបែរ ទើបត្រឡប់មកវត្តវិញ ។

ម៉ោង ១៨ ក្បួនហែដល់វត្តវិញ ។ ព្រះករុណាជាម្ចាស់ជីវិតលើត្បូង លោកកុម្មីស្ស៊ែរដឺឡារេពុយព្លិកបារាំង ព្រមទាំងព្រះរាជវង្សានុវង្ស ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី ប្រធានព្រះរាជអាណាចក្រ រដ្ឋមន្ត្រី តំណាងក្រសួង តំណាងព្រះរាជអាណាចក្រ នាម៉ឺនសព្វមុខមន្ត្រីបារាំង. ខ្មែររង់ចាំទទួលព្រះសពនៅព្រះពន្លាខាងត្បូងព្រះមេរុ ។

ក្រុមទាហានរក្សាព្រះអង្គ ក្រុមទាហានបារាំង នៅប្រចាំគំនាប់តាមទំនៀម ។

ម៉ោង ១៩ អុជប្រទីបថ្វាយ នៅទីវត្តសាកវិទេតជោ ទិសទីមេរុ ។

ម៉ោង ២០ និមន្តព្រះសង្ឃ ១៦ អង្គ ចំរើនព្រះបរិត្តក្នុងមេរុ

ប្រុសផ្ទុកទៀន ទឹកកាំស្រូវទ្វា ។

ម៉ោង ២១ និមន្តព្រះសង្ឃ ១ អង្គទេសនា, ៤អង្គទូលសព្ទៈ

១៦ អង្គសូត្រព្រះធម៌ក្នុងមេរុ ។

## ថ្ងៃទី ២ គឺថ្ងៃសៅរ៍ ៣ រោចខែផល្គុណ
## ២៧ ខែមីនា ឆ្នាំ ១៩៤៨

ម៉ោង ១០ ប្រគេនចង្ហាន់ព្រះសង្ឃ ១៦ អង្គដែលសូត្រព្រះធម៌ក្នុង

មេរុពីល្ងាច ទឹងព្រះសង្ឃឯទៀតចំនួន ២៥០ អង្គ ។

ម៉ោង ១៩ ដល់ម៉ោង ២៤ របៀបពិធីបុណ្យដូចថ្ងៃទី ១ ។

## ថ្ងៃទី ៣ គឺថ្ងៃអាទិត្យ ៤ រោចខែផល្គុណ
## ២៨ ខែមីនា ឆ្នាំ ១៩៤៨

របៀបពិធីបុណ្យដូចថ្ងៃទី ២ ។

ម៉ោង ៩ រំកិលព្រះកោដ្ឋចុះពីបញ្ញា ទៅដល់ក្នុងសាលាខាង

ទក្ខិណទិស រៀបគ្រឿងជាន់សម្រាប់បូជាសក្ការៈហើយនិមន្តតែឡកៈពាដ្ឋ

មកដំកល់លើគ្រឿងជាន់ក្នុងមេរុវិញ ។

ម៉ោង ១៧ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ស្តេចយាងព្រះរាជទានភ្លើង ជាមួយនឹងលោកកុម្មីស្សែនៃសាធារណរដ្ឋបារាំងសែស ប្រចាំប្រទេសកម្ពុជា ព្រមទាំងព្រះរាជវង្សានុវង្ស ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាព្រះរាជាណាចក្រ នឹងនាម៉ឺនសព្វមុខមន្ត្រីបារាំង-ខ្មែរ ។

ក្រុមទាហានរក្សាព្រះអង្គ ក្រុមទាហានបារាំង ក្រុមទាហានរក្សាព្រះនគរ ក្រុមពិជ័យសង្គ្រាម នឹងក្រុមភ្លេង[illegible] នៅប្រចាំគំនាប់ តាមទំនៀម ។

ម៉ោង ១៩ ដល់ម៉ោង ២១ រៀបចំពិធីបុណ្យសូត្រថ្ងៃទី២ តែគ្មានព្រះសង្ឃសូត្រព្រះធម្មទេ ។

## ថ្ងៃទី ៤ គឺថ្ងៃចន្ទ ៥ រោចខែផល្គុណ
## ២៩ ខែមីនា ឆ្នាំ ១៩៤៨

ម៉ោង ៧ និមន្តព្រះសង្ឃ៥អង្គសូត្រសត្តបករណាភិធម្ម រួចព្រះសង្ឃព្រមទាំងសិស្សានុសិស្សទាំងឡាយ រើសអដ្ឋិធាតុក្នុងធេដ្ឋប្រាក់ ក្រៅឡូពាស ដាក់លើពាន ២ ជាន់ ។

ម៉ោង ៨ និមន្តអដ្ឋិធាតុឡើងតម្កល់ក្នុងមេរុ ឯអង្គារៈនៅវិញយកទៅបញ្ចុះនៅកណ្ដាលទន្លេចតុមុខ ។

ម៉ោង ១០ និមន្តព្រះសង្ឃ ៤០ អង្គ មានរបៀបដូចក្នុងថ្ងៃទី ៤ ។

ម៉ោង ១៩ អុជប្រទីបផ្កាឈា នៅទីវត្តទីងទីទេរ ។

ម៉ោង ២០ ដល់ម៉ោង ២៤ និមន្តព្រះសង្ឃចំរើនព្រះបរិត្ត ទេសនា ប្រថមសម្ពោធិ រួចធ្វើកិច្ចពុទ្ធាភិសេក ក្រៅពីនោះមានកិច្ចធ្វើដូចក្នុង ថ្ងៃទី ១ មានអុជភ្លើងទៀន ទីងកាំជ្រួចជាដើម ។

## ថ្ងៃទី ៥ គឺថ្ងៃអង្គារ ៦ រោចខែផល្គុណ
## ៣០ ខែមីនា ឆ្នាំ ១៩៥៨

ម៉ោង ៦ និមន្តព្រះសង្ឃជយន្តោ ថ្វាយជយមង្គល បញ្ចប់កិច្ច ធ្វើពុទ្ធាភិសេក ។

### ពិធីដំកល់អដ្ឋិសម្តេចក្នុងប្រាង្គថ្មី

ម៉ោង ៩ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ស្តេចយាងទៅជា អធិបតី ជាមួយនឹងលោកកុំមីស្សែរនៃសាធារណរដ្ឋបារាំងសែស ប្រចាំ ប្រទេសកម្ពុជា ព្រមទាំងព្រះរាជវង្សានុវង្ស ប្រធានរដ្ឋសភា នាយក រដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាព្រះរាជាណាចក្រ រដ្ឋមន្ត្រីតំណាងក្រសួង ក្រុមប្រឹក្សាព្រះរាជាណាចក្រ និងនាម៉ឺនសព្វមុខមន្ត្រីបារាំង-ខ្មែរ ។

ព្រះថេរៈចន្ទសូត្រ សុទ្ធាឧជា ថ្លែងសេចក្តីសរសើរគុណសម្តេច ព្រះសង្ឃនាយក ចំពោះព្រះភក្ត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។

ព្រះមហាថេរ ១ អង្គ លើកកោដ្ឋអដ្ឋិសម្តេចថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។ ព្រះករុណាទ្រង់ទទួលអដ្ឋិជាសេចក្តីគោរពរួច ប្រគេនទៅព្រះមហាថេរនោះវិញ ហើយហែហូលទៅដាក់តម្កល់ក្នុងព្រាង្គ នៃព្រាង្គដែលសម្តេចបានកសាងជាអសោនកិច្ច ។

ម៉ោង ១០ ប្រគេនចង្ហាន់ព្រះសង្ឃជួបគ្នាថ្ងៃទី២ ។

ម៉ោង ១៤ និមន្តធម្មកថិក ៣ អង្គទេសនាសង្គាយនា ។

សំរេចការបុណ្យត្រឹមប៉ុណ្ណោះ

---

# វិភទ្ទញាណត្ថេរប្បវត្តិ

## ឃុនសិរីមេធី ស្រី-អ៊ូ

ក្រុមជំនុំព្រះត្រៃបិដក ក្រសួងពុទ្ធសាសនបណ្ឌិត្យភ្នំពេញ

រៀបរៀង

---

ព្រះវិភទ្ទញាណ សោម-ឡុច បិតានាម សោម មាតានាម មុំ កើតថ្ងៃអាទិត្យ ៥ កើតខែពិសាខ ឆ្នាំឆាលទោស័ក ព.ស. ២៤៣២ ត្រូវនឹងថ្ងៃ ១៨ មេ ឆ្នាំ ១៨៨៩ នៅភូមិក្រាំងត្រោក ឃុំភក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលអាយុ ១០ ឆ្នាំបាននៅសិក្សាអក្សរខ្មែរ ក្នុងសំណាក់លោកគ្រូស្មូត្រ អ៊ុំ វត្តកាត់ក្ដួច ឃុំផុន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដល់អាយុ ១៤ ឆ្នាំបានបព្វជ្ជាជាសាមណេរក្នុងសំណាក់លោកគ្រូចៅអធិការវត្តដដែល លុះបួសរួចហើយសាមណេរ សោម-ឡុច បានចេញទៅរៀនបរិយត្តិធម៌ក្នុងសំណាក់លោកអាចារ្យ ណុប (ឧបាសក) ក្នុងវត្តតាំងក្រពើ ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ អាយុ ២២ ឆ្នាំគិតក្នុងឆ្នាំកុរត្រីស័ក ព.ស. ២៤៥៥ គ.ស. ១៩១១ បានបំពេញឧបសម្បទាជាភិក្ខុក្នុងពទ្ធសីមាវត្តកាត់ក្ដួច បាននាមឆាយាជា សទ្ធម្មលិខិត មានលោកគ្រូព្រហ្មជោតជាឧបជ្ឈាយ៍ លោកគ្រូធម្មជោតជាកម្មវាចាចារ្យ លោកគ្រូសទ្ធម្មប្បញ្ញា ជាអនុសាវនាចារ្យ ។ ភិក្ខុសោម-ឡុច នៅក្នុងសំណាក់ព្រះឧបជ្ឈាយ៍បាន ១ វស្សា ក៏ទៅនៅវត្តស៊ុធរ ឃុំស៊ុធរ

ស្រុកខ្សាច់កណ្ដាល ខែត្រកណ្ដាល រៀនបរិយត្តិធម៌ក្នុងសំណាក់សម្ដេចព្រះធម្មលិខិតឧត្ដមប្រឹក្សាល្វី-ឯម គណមហានិកាយ បានធ្វើជាចៅ-អធិការវត្តនោះ ។ តមកទៀត ភិក្ខុសោម-ឡុច មកនៅវត្តកែវព្រះភ្លើង ក្រុងភ្នំពេញ រៀនបរិយត្តិធម៌ក្នុងសំណាក់ព្រះសាក្យវង្ស "ឃួន" ។ ក្នុងថ្ងៃព្រហស្បតិ៍ ខែផល្គុន ឆ្នាំឆ្លូវបញ្ចស័ក ព.ស. ២៤៥៧ បានចូលប្រឡងដេញប្រយោគ ក្នុងវត្តព្រះកែវមរកតក្រុងភ្នំពេញ ជាប់ទីមហា ៤ ប្រយោគ ។ កាលសម្ដេចព្រះធម្មលិខិតចេញពីវត្តស៊ីជរមកធ្វើជាចៅអធិការវត្តលង្កា ក្រុងភ្នំពេញ ព្រះមហាសោម-ឡុច ក៏ចេញពីវត្តកែវព្រះភ្លើង មកនៅវត្តលង្កា ក្នុងសំណាក់សម្ដេចព្រះធម្មលិខិត បានបង្រៀនបរិយត្តិធម៌ដល់ភិក្ខុសាមណេរក្នុងវត្តលង្កា តមកទៀតសម្ដេចបានចាត់ឲ្យទៅបង្រៀនបរិយត្តិធម៌នៅវត្តពោធិ៍ ស្រុកមោងឫស្សី ខែត្របាត់ដំបង អស់ ២ ឆ្នាំ ទើបត្រឡប់មកនៅវត្តលង្កាវិញ ។

ក្នុងឆ្នាំមមី ទោស័ក ព.ស. ២៤៧៣ គ.ស. ១៩៣០ ព្រះមហាសោម-ឡុច បានចូលធ្វើជាគ្រូជំនុំប្រែព្រះត្រៃបិដក ក្នុងក្រសួងពុទ្ធ-សាសនបណ្ឌិត្យ ភ្នំពេញ រៀងរហូតមក ។

ក្នុងឆ្នាំច ឆស័ក ព.ស. ២៤៧៧ គ.ស. ១៩៣៤ លោកគ្រូសេនីយមេទ័ពប្រទេសកម្ពុជា បានប្រ[illegible]សេចក្ដីសរសើរមួយច្បាប់ ព្រោះលោកបានជួយពន្យល់ផ្សាយសាសនាដល់ពួកទាហាន ។

ក្នុងឆ្នាំ ១៩៤៤ បានទទួលសមណសក្តិជាព្រះគ្រូមុនីសោភ័ណ ក្នុងឆ្នាំដដែលនោះបានទទួលសមណសក្តិជាព្រះវិន័យធម្ម ។

ក្នុងឆ្នាំម្សាញ់ត្រីស័ក ព.ស. ២៤៩៦ ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ទ្រង់បានព្រះរាជទានគ្រឿងឥស្សរិយយស មុនីសារាភរណ៍ ។

ក្នុងឆ្នាំមមែអដ្ឋស័ក ព.ស. ២៤៩៩ លោកបានទទួលសមណសក្តិជាព្រះធម្មមុនីទីពជាគណៈជាន់ឯកត្តា ដល់មកថ្ងៃ ៩ កក្កដា ១៩៤៧ បានទទួលសមណសក្តិជាព្រះវិសុទ្ធិញាណ ទីពជាគណៈជាន់ឯកត្តាដដែល ។

ព្រះវិសុទ្ធិញាណ សោម - ឡុច ធ្វើក្រមជំនុំព្រះត្រៃបិដក ជាអ្នកយកចិត្តទុកដាក់ក្នុងផ្នែកការងារ ប្រែពិនិត្យព្រះត្រៃបិដក ឥតទ្រាបទៀងទាត់ ដល់មកថ្ងៃ ១ មីនា (មាឃ) ១៩៤៨ ចាប់ឈឺជាទម្ងន់ហួសវិស័យពេទ្យព្យាបាលបានដល់ថ្ងៃពុធ ៨ កើតខែផល្គុន ឆ្នាំកុរនព្វស័ក ព.ស. ២៤៩០ ត្រូវនឹងថ្ងៃ ១៨ មីនា (មាឃ) ១៩៤៨ វេលាម៉ោង ១៧ លោកក៏ទទួលអនិច្ចធម្ម នៅមន្ទីរពេទ្យព្រះកេតុមាលាភ្នំពេញ ក្នុងជន្មាយុគំរប់៥៩ឆ្នាំ ។

សម្តេចព្រះធម្មលិខិតទុម្ពបរិក្សាគណមហានិកាយ ព្រមទាំងពួកសិស្សានុសិស្សទាំងឡាយ [illegible] បានការនាំសពមកដំកល់ទុកក្នុងសាលាឧបោសថវត្តលង្កា ហើយធ្វើកិច្ចបុណ្យតាមរៀងរាល់ថ្ងៃ រហូតដល់ថ្ងៃសៅរ៍ ១០ រោចខែផល្គុន ឆ្នាំដដែល ត្រូវនឹងថ្ងៃ ២ មេសា ១៩៤៨

វេលាម៉ោង ១៦ បានរៀបពិធីកិលសពដំកល់លើជើងយន្ត ដែលរចនាដោយក្បាច់ក្បូរផ្សេងៗ ហែចេញតាមផ្លូវវែងជំ ឧកញ៉ាអ៊ុំ-ប៊ុណ្ណារឿង ឧកញ៉ាឈុន បត់ចូលទៅវត្ត ឆ្ពោះទៅដំកល់ក្នុងបាក់យ៉ក់ដែលតាក់តែងដ៏វិចិត្រ វេលាម៉ោង ១៧ រៀបបូជាសព មានអាមុខសព្វមុខមន្ត្រីព្រះសង្ឃនាយកទាំង ២ គណៈ ពជាគណៈធំនិងហានុក្រម ព្រមទាំងពួកឧបាសកឧបាសិកា បានអញ្ជើញនិមន្តទៅជាអធិបតី បុណ្យដ៏ឧឡារិកសម្តេចព្រះវររាជបិតាស្តេចយាងទៅប្រទានភ្លើង មានសូត្រស្មូត្រកថា ២ លើក លើកទី ១ កំណាព្យពួកសិស្សានុសិស្ស ឧបាសកឧបាសិកាចំពោះវត្តលង្កា លើកទី ២ កំណាព្យនៃក្រសួងពុទ្ធសាសនបណ្ឌិត្យ ។

នេះជាសូត្រកថាលើកទី ២ កំណាព្យនៃក្រសួងពុទ្ធសាសនបណ្ឌិត្យជូនសោកក្ដីទៅនេះ :

## វិយោគគាថា

ព្រះករុណាគ្រប់ព្រះអង្គ !

ព្រះតេជ-គុណ និង លោកសប្បុរសទាំងឡាយ !

ខ្ញុំព្រះករុណា ជំណាន់ព្រះថេរានុគ្រោះ, អស់លោកសក្តិផលក្រុមជំនុំព្រះត្រៃបិដក, លោកគ្រូគាថារៀសា ណាភក្ខុ ខ្ពស់ និងអស់លោកនៃក្រសួងពុទ្ធសាសនបណ្ឌិត្យ, សូមគន្ទាភកន្តុំព្រះករុណាថ្លែងពិគ្គិ-គុណនិងសោកក្ដីសោ-ស្តាយព្រះតេជ-គុណ សោរ-ឌ្យូប ព្រមទាំង

សូមបូលកាន់ដំណែងញ្ញាប់ពោះវិញ្ញាណក្ខន្ធរបស់ព្រះថេរៈអង្គនេះ ក្នុង ទុកសម្រាប់ល្បាយបដិបត្តិបទេសត្ថុខទាំងនេះ ។

ព្រះតេជព្រះគុណ សោម ឡុច នេះជាសង្ឃដ៏ជាចារ្យមួយដ៏ប្រសើរ ដែលត្រូវបានជាអ្នកប្រាជ្ញជាន់ខ្ពស់មួយក្រោមត្រីប្រឹក្សា ណែនាំមន្ត្រីប្រាជ្ញ ក្នុង ព្រះពុទ្ធសាសនា ។ លោកជាពហុស្សូតបេះដាំ ស្គាល់ជំនាញខាងវិន័យ-បិដកនិងអភិធម្មបិដក, លោកតែងធ្វើការស្រាយបកស្រាយធម៌វិន័យអស់ផ្លូវ គាត់ហួសជួបវិល ត្រឹមត្រូវតាមបទមាតិកាឥតខ្ចោះ ដល់សហការីក្នុង ក្រុមជំនុំ ដែលត្រូវការសោរស្សូវ ពីព្រោះនិងលោកៗ តែងមានចិត្តព្រះ ករុណាញញឹមស្រស់ស្រាយ ជាលក្ខណៈសម្បត្តិនៃអ្នកប្រាជ្ញដែលប្រកប ដោយប្រាជ្ញាជ្រៅជ្រះ ។ លោកជាអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនា មានចំណេះចេះដឹងជ្រាលជ្រៅ, ពន្យល់ពាយ, រកគួរប្រៀបផ្ទឹមដោយពិបាកៗ

ព្រះតេជព្រះគុណ សោម - ឡុច នេះជាធម្មកថិកជាន់ឯកមួយ ល្បី ព្រះនាមខ្ចរខ្ចាយទៅក្នុងទិសានុទិសនៃកម្ពុជរដ្ឋ ។ លោកជាអ្នកព្យាយាម ធ្វើការមិនអន់ថយទាំង ។ ជីវិតលោកពេញដោយការងារ ជាជីវិតមិន ចេះសាបសូន្យ ។

នៅក្នុងក្រុមជំនុំប្រែព្រះត្រៃបិដក, ព្រះតេជព្រះគុណ សោម - ឡុច នេះជាប្រទីបមួយគាបព្រោលបំភ្លឺមន្ទីរ ឲ្យមានពន្លឺភ្លឺច្រាលច្រាយស្វាង ត្រចះ ។ លោកជាទីគោរពរាប់អានពេញចិត្ត នៃក្រុមជំនុំទាំងឡាយ មិន

ថាគណៈណា ទិកាលណា ; មានពុទ្ធដីកាទៅកាន់លោក [illegible] តែងតែនាំ
យកសេចក្តីរីករាយសប្បាយចិត្ត នាំឲ្យកើតថ្ងៃប្រមាត់ ឲ្យធ្វើការ គនាំ
ឲ្យសោរគ្រាគចិត្តជាមួយលោកឡើយ ។ លោកបានព្រះទិយ [illegible]
ក្តុខ, មានពុទ្ធដីកាពីពេរស្រេចន់ [illegible]
លោកគិតតែធ្វើការដែលនាំឲ្យកើតសេចក្តីសុខ [illegible] តែមួយគេហើយ ។

ព្រះតេជព្រះគុណ សោម-ឡូ [illegible] ស្រឡាញ់ពេញព្រះទ័យនឹង
ការគ្រប់គ្រងថ្វើព្រះត្រៃបិដក [illegible] មើលមន្ទុះទៅលោក [illegible] មិន
ដែលបានលះបង់ពេលការងារឡើយ ។ លោកទុកការងារនេះជា
ជីវិតរបស់លោក, ដូចជាលោកបានចុះសញ្ញា [illegible] លោកចំពោះព្រះ
ពុទ្ធសាសនាដូច្នោះឯង ។

ពេលនេះ ព្រះតេជព្រះគុណ សោម-ឡូ ដែលយើងបានពោល
សរសើរកិត្តិគុណមកនេះ ផុតកិច្ចនឹងរស់នៅ [illegible] ទៀតហើយ លោក
និមន្តទៅកាន់ចារលោកហើយ ទុកនៅសល់តែការងារជាស្នាដៃលោក
ជាស្នាដៃមិនចេះស្លាប់ ។

ការព្រាត់ប្រាសនិកស់នេះ នាំឲ្យកើតសេចក្តីសោកស្តាយ
ស្រណោះអាលោះអាល័យឥតស្រាកស្រាន្ត ។

បណ្ដាអ្នកមជ្ឈដ្ឋានពុទ្ធសាសនា [illegible]
នេះហើយ ក៏មានចិត្តតក់ស្លុត [illegible]

ចក្រឡប់គ្នា ។ ខ្ញុំបានមុខហ្វូងហៀរ ដោយសម្បុរស្លេក ស្រាប ស្រពកស្រពោន ពណ៌ខ្មៅក្រៀមក្រំ ។ ខ្ញុំ ស្លូតធ្លាប់ហើយ អស់កម្លាំងហាក់គ្មានកម្លាំង គាប មកពីក្រែងកប៉ាល់ ព្រះអង្គព្រះគុណនេះបញ្ជាក់ឲ្យបើកលក់គ្នាទៅ ជក កាណាំតកាស្ដួរ យើងបង្ខិតនោះ ។

មន្ទីរក្រុមជំនុំប្រែព្រះត្រៃបិដក ដែលធ្លាប់តែតាំងព្រះថេរៈគង់នេះគង់ នៅជាពន្លឺពណ្ណរាយ ផ្កាឈូក ក៏ខ្ពុរយ៉ាងបរិសុទ្ធ ។ មានតារាង ដូចជាតែងតែនៅជាមួយជុំ មកប៉ុនតែព្រះអាទិត្យព្រះចន្ទ ឬមាន កាកាដូចកុកត្រសក់ក្បែរទៀតកង់កៅលាប់ប៉ង់ចិតសួនឈើ ហើយត្រូវ ខ្យល់កំណាចប៉ោកមកម័ត្តគំរាមក្បែរក្បៀននានោះដូចោះឯង ។

មន្ទីរដែលធ្លាប់ផ្ដល់ជីវិតស្រីយ ព្រះតេជព្រះគុណនេះ បើ ពិចារណាកើតនៅទៀត មិនមែនមានផ្លូវណាក្រៅតែអាយុជីវិតមួយ ព្រះអង្គប៉ុណ្ណោះទេ ថែមទាំងបួលមកសម្រាប់កិច្ចការផ្សេងៗទៀតផង ។ ព្រះអភិធម្មបិដកសព្វថ្ងៃនេះ ជាការនៃព្រះថេរៈគង់នេះផ្ទៀងផ្ទាត់ក៏ស្គម ដំណើរពោកកណ្ដាលដូរមួងទៀត ។ ក្រុមជំនុំព្រះត្រៃបិដកខាតមេគំនិត ប្រសើរមួយ ព្រះពុទ្ធសាសនាខាតធម្មកថិកវិសេសមួយ សម្រាប់ សម្ដែងធម៌ទេសនាប្រោសពុទ្ធបរិស័ទ ។

ការខាតសហការីជាមេគំនិតធំនេះ ទុកដូចជារណ្ដៅដែលរូងខ្ពង ជ្រៅធ្លាយ ទុកតែតាក់ដីបំពេញឲ្យមានសណ្ឋានរាបស្មើល្អវិញនោះ

គេនឹងប្រើពេលវេលាយូរឆ្នាំណាស់ ។ ការស៊ូវក៏ដោយ តែនៅតែមានទុបសត្វមានអង្គភាពកាំងពីមុនដកបយាននេះឯង ។

ព្រះតេជព្រះគុណ សោម-ឡុងខេ ពិតមែនតែរូបអ្នកវេងប៉ុន្តែ ពេលនៃរូបរក្សាពុទ្ធឥករណ៍សម្បត្តិដ៏ប្រសើរ រៀបរយ, ស្មាតែឯក រស់នៅរហែង ជាទំរូធ្លាក់ជាប់នៅក្នុងជំពូកសាហាការ ត្រូវគ្នា ណោះ ក្នុងសម្បត្តិដ៏ប្រសើរ ក្នុងចំណោមអ្នកប្រសើរទាំងឡាយ លោកសុខចិត្តទទួល អធិប្បាយដោយពោលថា "ឲ្យគ្នា" មិនត្រូវស្មារតីមិនសប្បាយ ទៅតាមចរលោកជួបបុគ្គលនោះពោលថា "សេក្តីតាប់ ក៏ប៉ុន្តែ ចុះស៊ូស្លាប់ទៅជា សេដ្ឋកិច្ចបង្គំ ។ លោកកើតឡើងធ្វើការ ធ្វើការទៀត ក៏ធ្វើការទៅវាលទំនេរកាតវិញ ស្លាប់ទៅវិញទុកការងារឲ្យរស់នៅក្នុងលោក, រស់នៅតែមួយថ្ងៃ ធ្វើការយោលបន្សល់ទុកព្រះសម្មាសម្ពុទ្ធ ព្រោះផលប្រសើរជារៀងរស់នៅមួយរយឆ្នាំ ។

ព្រះតេជព្រះគុណ ពេលនេះ យើងខ្ញុំទាំងឡាយមកជួបជុំគ្នា ពោលសរសើរគុណគុណគេចក្តីសោកស្តាយ ហើយពោលទៀត ធ្វើតែមិនចប់មិនហើយ ដោយសេចក្តីស្រណោះការណោះអាល័យជាបំផុត យើងកាលគ្នានៅបន់តែរូបខ្ញុំព្រោយ ព្រះគុណ សំដី គុ គៅគីរិដលគន្ធយ ធ្លាប់ធ្វើការជាមួយគ្នា ពេលមិនចេញចូល ស្រម៉ៃ ឃើញព្រះតេជព្រះគុណរីករាយសប្បាយចូលចេញជាមួយគ្នា ។ ទុព្រះ

តេជព្រះគុណថ្ងៃណា ហ៊ើយយើងនឹងបានជួបគ្នាទៀត យើងមានតែទន្ទឹងខ្សឹកខ្សួលក្នុងចិត្ត មិនដឹងជាថ្ងៃណា យើងនឹងបានសួរទុក្ខដូចនេះទេ ៗ ណ្ហើយព្រះតេជព្រះគុណ ព្រះតេជព្រះគុណនិមន្តទៅមុនយើង សូមកុំភ្លេចការងារយើងដែលយើងបានធ្វើរួមជាមួយគ្នា ហើយបានជាគ្រឿងឈ្មោះប្រសើរដល់ប្រទេសកម្ពុជា ជាទីស្រឡាញ់របស់យើង គ្រឿងឈ្មោះនេះអណ្ដែតត្រសែតទៅដាក់សកលលោកទាំងមូល គេសរសើរប្រទេសកម្ពុជាយើងគ្រប់គ្នា ។ ខ្ញុំព្រះករុណាសូមយកសេចក្ដីសរសើរនោះ មកប្រគេនទុកជាបច្ឆិមវចនៈ ពាក្យចុងបំផុត ទុកជាទីរឭកឲ្យកើតបីតិប្រាមោជ្ជ កើតសេចក្ដីសុខ-ចំរើន ៗ

ព្រះតេជព្រះគុណ ពីរបីខែមុនទៅថ្ងៃនេះ មានអ្នកប្រាជ្ញបារាំងម្នាក់ជាចាងហ្វាងសមាគមឥណ្ឌានៅសូរបោន (Société indienne à la Sorbonne) បានចូលមកមើលមន្ទីរព្រះត្រៃបិដកយើង បានសាកសួរដេញដោលយើង ពីរបៀបប្រែព្រះត្រៃបិដក និងបោះពុម្ព យើងបានឆ្លើយប្រាប់សព្វគ្រប់តាមដំណើរលុះចប់ការសន្ទនាហើយ គេនិយាយថា « ការស្រាយមកប្រែជាភាសាខ្មែរបោះពុម្ពផ្សាយនេះ ជាការប្រសើរណាស់ មិនដែលមានប្រទេសណាយកព្រះត្រៃបិដកគ្រប់ភាសាលង្កា-ភូមា-សៀម-ចុះមកផ្ទៀងគ្នាមើល ដូចប្រទេសខ្មែរទេ-ការងារនេះ

ធំណាស់ ល្អិតល្អប្រសើរណាស់; ប្រទេសបារាំងនឹងធ្វើតាមគម្រាប់នេះនៅក្រុងប៉ារីស” ។

នៅកោះលង្កា, គេបានផ្សាយតាមកាសែតច្បាប់ជនជាតិលង្កាថា “នៅប្រទេសខ្មែរ គេសង្គាយនា បោះពុម្ពព្រះត្រៃបិដកជាភាសាគេ, ជាបាឡីទំព័រម្ខាង - ជាភាសាខ្មែរទំព័រម្ខាង - ស្រុកគេតូច មានអ្នកប្រាជ្ញចេះដឹងច្រើនធ្វើការធំណាស់ មិនដែលមានក្នុងប្រវត្តិពុទ្ធសាសនា តាំងពីព្រះបរមគ្រូទ្រង់បរិនិព្វានទៅ, តែគេមិនអួតខ្លួន គួរឲ្យសរសើរណាស់” ។

ប្រទេសដែលកាន់ព្រះពុទ្ធសាសនាសុទ្ធតែបានដឹងច្បាស់ថាការបោះពុម្ពព្រះត្រៃបិដក មិនជារឿងតូចទេ, ជាកេរ្តិ៍ឈ្មោះប្រទេសកម្ពុជា ដែលពោកតាំងមកមិនដែលឮឈ្មោះដល់ម្លឹងនោះ ។ កេរ្តិ៍ឈ្មោះនេះកើតចេញពីស្នាដៃព្រះតេជព្រះគុណមួយចំណែកដែរ ជាកំពើប្រសើរមួយមិនមានទំពីរក្នុងលោកនេះឡើយ ដែលអណ្ដែតនៅជាប់ក្នុងដួងចិត្តប្រទេសទាំងឡាយក្នុងលោក, ជាកេរ្តិ៍ឈ្មោះនាំឲ្យកើតសេចក្ដីសុខ-ចំរើនលោកត្រជាក់ថែបសន្តិភាពទៅតែមួយចំណែក ។

សូមព្រះតេជព្រះគុណពេញព្រះទ័យ ជឿជាក់ក្នុងព្រះទ័យដោយយល់ថា “អាត្មាអញបានបំពេញធុរណីយកិច្ចរបស់មនុស្សជាតិ ពេញបរិបូណ៌ហើយ” មួយទៀត យើងខ្ញុំទាំងឡាយសូមប្រមូលបុញ្ញាភាសយើង

គ្រប់គ្នាលើកលើសិរសាដំកល់ទុកជាធម្មបណ្ណាការដ៏ខ្ពង់ខ្ពស់ប្រសើរឧត្តុង្គ ប្រគេនព្រះតេជព្រះគុណ សូមមេត្តាទទួលយកដោយរីករាយ សូមឲ្យបានសម្រេចជាបត្តានុមោទនាមយៈ ហើយសូមឲ្យបានប្រកបដោយសិរីសួស្តីជ័យមង្គលវិបុលសុខគ្រប់ប្រការតរៀងទៅ ។

ទីបំផុត យើងខ្ញុំទាំងឡាយសូមខមាទោសចំពោះព្រះតេជព្រះគុណ សេចក្តីឆ្គងលើសលស់ដោយកាយវាចាចិត្តក្តីណា ឬ ក្នុងទ្វារណាមួយ សូមព្រះតេជព្រះគុណអភ័យទោសដោយករុណាភាពឲ្យបាន ។

---

# ចក្កធម៌

## របស់ព្រះវិន័យធម្មយូរ · ប៊ុណ្ណ

នៅវត្តឧណ្ណាលោម នាក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

តពីនមស្សការនេះទៅ ខ្ញុំនឹងលើកយកចក្កធម៌មកសំដែងក្នុងទីនេះ ដើម្បីជាទីសវនាការដល់អស់លោកអ្នកជាពុទ្ធបរិស័ទទាំងឡាយ ដូចតទៅនេះ

---

ចក្កធម៌ ធម៌ដូចជាកង់រមែងវិលទៅកាន់សេចក្ដីចំរើនមាន ៤ យ៉ាងគឺ

១ បដិរូបទេសវាសៈ នៅក្នុងប្រទេសដ៏សមគួរ

២ - សប្បុរិសូបស្សយៈ សេពគប់នឹងសប្បុរស

៣ - អត្តសម្មាបណិធិ តាំងខ្លួនបានដោយប្រពៃ

៤ - បុព្វេកតបុញ្ញតា ភាពជាអ្នកបានធ្វើសេចក្ដីល្អទុកមកពីក្នុងកាលមុន ។

ធម៌ ៤ យ៉ាងនេះ ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងប្រៀបដូចជាចក្ក, ធម្មតាចក្ក ឬរថ កាលបើបុគ្គលមានបំណងបរទៅកាន់ទីណាមួយហើយ រមែងនាំទៅកាន់ទីនោះបានតាមប្រាថ្នា យ៉ាងណាមិញ ធម៌ ៤ យ៉ាងនេះបើបុគ្គលបានប្រព្រឹត្ត បានធ្វើឲ្យសមហេតុសមផលហើយ ក៏រមែង

ធ្វើសេចក្តីចំរើនឲ្យកើតឡើងដោយលំដាប់តាមជាន់តាមថ្នាក់បាន ក៏យ៉ាងនោះដែរ ។ សូមលើកយកចក្កធម៌ទី ១ មកសំដែងតទៅ គឺ:

១ បដិរូបទេសវាសៈ ប្រែថា នៅក្នុងប្រទេសដ៏សមគួរនោះ គឺប្រទេសណាដែលសម្បូណ៌ដោយអ្នកប្រាជ្ញចេះដឹងច្រើន ប៉ិនប្រសប់ខាងការរៀបចំប្រជាជាតិឲ្យសិក្សាចំណេះវិជ្ជា និងធម៌អាថ៌ផ្លូវព្រះពុទ្ធ-សាសនាជាគ្រឿងប្រដៅចិត្តឲ្យមានមេត្តាករុណាធម៌ ចេះសង្គ្រោះគ្នា ចេះស្រឡាញ់រាប់រកគ្នា ចែកសេចក្តីសុខដល់គ្នា ប្រាប់ប្រយោជន៍ដល់គ្នា ដើម្បីញុំាងប្រជាជាតិជាមួយគ្នាឲ្យថ្កុំថ្កើងការចេះដឹង, ប្រទេសយ៉ាងនេះ ហៅថាប្រទេសដ៏សមគួរ ជាប្រទេសប្រកបដោយធម៌ ។

មួយទៀត ប្រទេសណា មានព្រះមហាក្សត្រសោយរាជ្យប្រកបដោយទសពិធរាជធម៌ ចាត់ចែងរាជការតាមប្រវេណីរបស់ព្រះមហាក្សត្រទ្រង់ធម៌ មានសេចក្តីអនុគ្រោះដល់ប្រជារាស្ត្រ រៀបចំប្រជាជាតិឲ្យសិក្សាចំណេះវិជ្ជាទាំងផ្លូវលោកនិងផ្លូវធម៌ឲ្យគប់គ្រាន់គឺវិជ្ជាអក្សរសាស្ត្រ លេខនព្វន្ត និងសិល្បកម្មផ្សេងៗ សម្បូណ៌ទៅដោយស្រែចម្ការច្បារដំណាំ ទាំងរបរខាងផ្លូវសេដ្ឋកិច្ច ពាណិជ្ជកម្ម កសិកម្ម និងសម្បូណ៌ដោយ ស្ទឹង បឹង ព្រែក ទន្លេ សម្រាប់អ្នកដែលត្រូវការមានការបង្ហូរទឹកចេញចូលដាក់ស្រែចម្ការច្បារដំណាំជាដើម ព្រមទាំងគ្រឿងប្រើប្រាស់

គ្រឿងបរិភោគ ឧបភោគ គ្រឿងស្លៀកពាក់ និងគ្រឿងការពារសត្រូវ ជាដើម; យ៉ាងនេះហៅថា ប្រទេសដ៏សមគួរតាមផ្លូវលោក ។

ទាំងប្រជាជាតិដែលមានភ័ព្វសំណាងកសាងមកកើតចួបប្រទះនឹង សេចក្ដីសុខ-ចំរើន ក្នុងប្រទេសដែលសម្បូណ៌ដោយចំណេះវិជ្ជា ភោគសម្បទដូចបានពោលហើយខាងលើនេះទៀតហោង ក៏ត្រូវតែ កសាងកំឡាំងកាយ គឺជា ចិត្តឲ្យរឹងប៉ឹង តាំងសេចក្ដីព្យាយាមកាប់បំបាក់ ទិសស្បៀយចោនពាប ខ្ជិលច្រអូសធុញទ្រាន់ ប្រមាទមំមេងាយគោះ ចោលចេញ ហើយផ្ចិតកាយ គឺជា ចិត្តឲ្យរឹងប៉ឹង ក្លៀវក្លាមានក្ដី មានឧបាយសមគួរទាំងតស៊ូរកនឹងកិច្ចការងារគ្រប់យ៉ាង ឲ្យដុះដាលលូតលាស់ចំរើនឡើង ដើម្បីនឹងបង្វិលភ័ព្វសំណាងដែលកសាងជាកទាប នោះ ឲ្យវិលទៅកាន់សេចក្ដីចំរើន កុំបណ្ដោយកសាងទៅតាមអំពើចិត្ត កុំដេកចាំព្រេងសំណាងនោះមិនបានទេ ឯព្រេងសំណាងដែលនឹងផ្ដល់ឲ្យនោះ លុះតែខំប្រឹងរៀនប្រឹងរក ប្រឹងប្រព្រឹត្ត ទើបជាកសាងនឹងផ្ដល់ឲ្យតាមលំដាប់ខ្ពស់ទាប; យ៉ាងនេះហៅថា នៅក្នុងប្រទេសដ៏សមគួរ ។

ប្រទេសនីមួយៗ ដែលនឹងលូតលាស់ចំរើនឡើងទៅតាមបំណងជាន់ខ្ពស់បាន, លុះតែប្រកបដោយផ្លូវទាំងពីរយ៉ាង គឺផ្លូវលោក និងផ្លូវធម៌ អាស្រ័យគ្នា ប្រព្រឹត្តទៅជាមួយគ្នា ដើរទៅទន្ទឹមគ្នា ទើបបាននឹងចំរើនរុងរឿងសុខក្សេមក្សាន្តបាន ។ ផ្លូវទាំងពីរនេះតែងដើរទៅជាមួយ ផ្លូវ

លោភទៅត្រង់ណា ផ្លូវធម៌ក៏ទៅត្រង់នោះ, ផ្លូវធម៌ទៅត្រង់ណា ផ្លូវលោភក៏ទៅត្រង់នោះដែរ, ផ្លូវលោភស្ថិតនៅយូរប៉ុណ្ណា ផ្លូវធម៌ក៏ស្ថិតនៅយូរប៉ុណ្ណោះដែរ ។ បើមានតែផ្លូវធម៌ម្យ៉ាង មិនមានការរៀបចំឲ្យមានគ្រោងការរក្សាប្រទេស នឹងសម្បត្តិរបស់ប្រទេសទេ, ប្រទេសក៏នឹងក្លាយទៅជាក្រីក្រលំបាកទៅជាព្រៃផ្សៃ ទៅជាប្រទេសមិនមានតម្លៃទៅវិញ ។ ឬក៏មានតែផ្លូវលោភម្យ៉ាង ប្រទេសក៏នឹងក្លាយទៅជាភ្លើងឆេះពេញលោកទាំងមូល, ព្រោះមនុស្សប្រកបដោយលោភៈ ទោសៈ មោហៈ ច្រើន មិនមានមេត្តាករុណាធម៌សម្រាប់លត់ភ្លើង គឺ លោភៈ ទោសៈ មោហៈ នោះឡើយ ។

ព្រះពុទ្ធជាម្ចាស់ទ្រង់ឈ្វេងយល់ហេតុផលនេះហើយ ទើបទ្រង់សំដែងផ្លូវទាំងពីរប្រការនេះឲ្យសត្វធ្វើតាម ប្រព្រឹត្តតាម, ដើម្បីនឹងញុំាងប្រទេសទាំងមូលឲ្យដើរទៅកាន់សេចក្តីសុខ-ចំរើនតទៅ ។

ការដែលអាស្រ័យនៅក្នុងប្រទេសដ៏សមគួរដូចបានពោលមកនេះ រាប់ថាជាមង្គល ១ យ៉ាងប្រសើរក្នុងលោក ហៅថាបក្ខធម៌ទី ១ ។

ទី ២ - សប្បុរិសូបសំសេវៈ: សេចក្តីគប់នឹងសប្បុរសមាន សេចក្តីថា បណ្តាមនុស្សក្នុងលោក សូម្បីមានកំឡាំងកាយ កំឡាំងប្រាជ្ញា កំឡាំងគំនិត សម្រាប់ចិញ្ចឹមជីវិតរបស់ខ្លួននឹងអ្នកដទៃ, ឬឲ្យសម្រេចប្រយោជន៍ជួយដល់ក្រុមញាតិសាច់សាលោហិត រហូតដល់

ប្រទេសជាតិ មិនឲ្យវិនាសក្ស័យ តាំងធ្វើបុកពាមារយាទឲ្យល្អកើតឡើងបាននោះ កំត្រូវតែធ្វើសេចក្ដីសុទ្ធស្អាតសោតគប់នឹងសប្បុរសជាមុន ដើម្បីនឹងឲ្យស្គាល់ហេតុផលទំនងការនោះសិន ទើបកិច្ចការនោះដើរទៅកាន់សេចក្ដីសុខ-ចំរើនបាន ។

ឯបុគ្គលជាសប្បុរសនោះមិនកំណត់រូបណាមួយឡើយ ទោះបីបុរស, ស្ត្រី, គ្រហស្ថ, បព្វជិត ឲ្យតែមានចរិយល្អ បិតនៅក្នុងធម៌របស់សប្បុរស ឈ្មោះសកាន់រៀរប៉ុនប្រែសប់ចេះដឹងផ្លូវលោក ផ្លូវធម៌បរិបូណ៌ ក៏ហៅថាសប្បុរសទាំងអស់ ។ សប្បុរសនេះជាបុគ្គលថ្លៃថ្នូក្នុងលោក កាចយកចិត្តទុកដាក់ជួយស្រោចស្រង់ដោះទុក្ខប្រជាជាតិមាតុភូមិ ឲ្យឡើងទៅកាន់ថ្នាក់ជាន់ខ្ពស់បាន ។

ហេតុនេះ យើងជាអ្នកស្រឡាញ់សេចក្ដីសុខ-ចំរើន ត្រូវតែផ្ចិតចំឡើងយកបែបបទសណ្ដាប់ធ្នាប់ ការចេះដឹងពីលោកឲ្យបានគ្រប់គ្រាន់ទាន់សម័យ កុំបង្អង់ឲ្យពេលវេលាកន្លងទៅ ដើម្បីសាងជាតិឲ្យរីកធំហើយមួយ កើតខ្លួនឲ្យផុតចាកការជោកជាបដែលបានទទួលគ្រោះថ្នាក់ពីសេចក្ដីល្ងង់ខ្លៅក្រៃត្រលំបាកពោលពេញ ។

មួយទៀត សប្បុរសនេះ បើនរណាបានចូលទៅគប់រកប្រសប់យកជាមិត្ត ឬសូមធ្វើជាគ្រូអាចារ្យ ហើយទស្សនារៀនសូត្រប្រតិបត្តិតាម ប៉ុន្តែជាមិនធ្លាប់ជាបណ្ឌិតមកពីដើម ក៏គង់ក្លាយទៅជា

បណ្ឌិតតាមលោកមិនលែង ព្រោះលោកនោះឯង តែងមានឧបាយបេះ ឱយាយណែនាំអ្នកដែលចូលទៅសេពគប់នឹងលោកនោះ ឲ្យប្រព្រឹត្ត តាមផង ។

សប្បុរសមានគុណគឺសេចក្ដីល្អគួរគប់រកាន មានគួរនោះដូចគ្រឿង ក្រអូបមានក្រស្នា ទឹកម្រេងផ្កាជាដើម ឯអ្នកដែលចូលទៅគប់ប្រៀបបី ដូចជាស្លឹកឈើឬសំពត់ដែលខ្ចប់ដែលរុំគ្រឿងក្រអូបនោះ ទោះបីស្លឹក ឈើ ឬសំពត់នោះមិនមានក្លិនក្រអូប ក៏ក្លាយទៅជាមានក្លិនក្រអូបតាម សេចក្ដីនេះ សមដូចពុទ្ធភាសិតថា

តគ្គរញ្ច បលាសេន យោ នរោ ឧបនយ្ហតិ
បត្តាបិ សុរភី វាយន្តិ ឯវំ ធីរូបសេវនា ។

សេចក្ដីថា នរជនណារុំខ្ចប់ខ្លឹមក្រស្នាដោយស្លឹកឈើ បើទុក ជាស្លឹកឈើ (មិនធ្លាប់ក្រអូបពីដើម) ក៏គង់តែក្លាយទៅជាក្រអូបល្ហួយ ល្ហប់គួរឲ្យជាប់ចិត្ត យ៉ាងណាមិញ៖ ការដែលចូលទៅសេពគប់នឹង លោកអ្នកប្រាជ្ញ (ក៏មានកិត្តិសព្ទក្រអូបខ្ចរខ្ចាយ) ក៏យ៉ាងនោះដែរ ។

សប្បុរសនេះ លោកមិនមែនពន្យល់ប្រាប់តែផ្លូវសុខសួគ៌និព្វាន ដែលយើងមើលមិនឃើញនោះទេ គឺលោកបង្ហាញផ្លូវបច្ចុប្បន្នដែលមើល ឃើញជាក់ស្ដែងនឹងភ្នែកផង ដូចជាពន្យល់ឲ្យរៀនចំណេះវិជ្ជា ឲ្យប្រឹង ប្រែងរកទ្រព្យសម្បត្តិ កុំឲ្យសេពគប់នឹងបុគ្គលពាលដូច្នេះជាដើម ។

ព្រោះហេតុនោះ សាធុជនទាំងឡាយ កាលបើបានជ្រាបសេចក្តីដែលបានពោលហើយខាងលើនេះ គួរសេពគប់នឹងសប្បុរសចំណែកមួយពុះ កុំសេពគប់នឹងបុគ្គលពាលជាដាច់ខាត, បើប្រទេសយើងទាំងមូលមិនមានសប្បុរសម្នាក់សោះ មានសុទ្ធតែមនុស្សពាល ក៏កុំគប់ប្រសប់ឡើយជាដាច់ខាត ។

ការសេពគប់នឹងសប្បុរស ដូចបានសំដែងហើយខាងលើនេះ រាប់ថាជាចក្កធម៌ទី ២ ។

ទី ៣- អត្តសម្មាបណិធិ ប្រែថា ការតាំងខ្លួនបានដោយប្រពៃនោះគឺបុគ្គលកាលបើបានសេពគប់នឹងសប្បុរសបានសិក្សារៀនចំណេះវិជ្ជា ផ្តិតបំឡង់យកបែបបទសណ្តាប់ធ្នាប់ពីលោកបានហើយ ត្រូវផ្តាច់និស្ស័យថោកទាបគឺគំនិតទាស់ដែលធ្លាប់កាន់ ធ្លាប់ជឿ ធ្លាប់ប្រព្រឹត្តធ្លាប់ខ្ជិលច្រអូស ធុញទ្រាន់ ធ្វេសប្រហែសនោះចោលចេញ ហើយស្រង់ទុកត្រសោបចាប់យកនិស្ស័យជាន់ខ្ពស់ ដែលបានសន្សំអប់រំនោះមកដាក់កលទុកក្នុងដួងចិត្តរបស់ខ្លួន, ដើម្បីនឹងសាងអត្តភាព នឹងប្រទេសជាតិមាតុភូមិ ឲ្យឡើងទៅកាន់ការ្យធម៌ជាន់ខ្ពស់, យ៉ាងនេះហៅថាការតាំងខ្លួនបានដោយប្រពៃ ។

ឯគ្រឿងការដែលកសាងអត្តភាព នឹងប្រទេសជាតិមាតុភូមិ ឲ្យឡើងទៅកាន់ការ្យធម៌ជាន់ខ្ពស់នោះ សំដៅយកប្រយោជន៍ពីរប្រការ គឺ

ប្រយោជន៍ដែលត្រូវបានឃើញទាន់ក្នុងជាតិនេះ ហៅថា ទិដ្ឋធម្មិក-ប្រយោជន៍ ១ ប្រយោជន៍ដែលត្រូវបានក្នុងកាលខាងមុខ ហៅថាសម្បរា-យិកប្រយោជន៍ ១ ។

ទិដ្ឋធម្មិកប្រយោជន៍ ជាហេតុឲ្យបានសេចក្ដីសុខ ចំពោះក្នុងជាតិនេះអស់មួយជីវិត, ចែកចេញជា ៤ យ៉ាងគឺ :

១- ការបរិបូណ៌ដោយសេចក្ដីព្យាយាមប្រឹងប្រែងប្រកបកិច្ចការងារ រកស៊ីចិញ្ចឹមជីវិតដោយកិច្ចដែលត្រូវធ្វើផ្សេងៗ ទាំងចំណេះវិជ្ជាគ្រប់បែប ឯកឯងដល់បានភោគសម្បទ៍ដែលជាផលកើតមកអំពីហេតុគឺសេចក្ដីខ្មីឃ្មាត ប្រកបការងារនោះៗ ហៅថាឧដ្ឋានសម្បទា ។

២- ការបរិបូណ៌ដោយការបីបាច់រក្សាថែទាំទ្រព្យសម្បត្តិដែលខ្លួនរកបានមកនោះ មិនឲ្យខូចខាតអន្តរាយដោយហេតុមិនគួរនឹងអន្តរាយ មានអបាយមុខជាដើម ហៅថាអារក្ខសម្បទា ។

៣- ការចេះចាយវាយទ្រព្យសម្បត្តិចិញ្ចឹមជីវិតល្មមសមគួរដល់កំឡាំងទ្រព្យដែលរកបាន មិនរ៉ះពេក មិនកញ្ចះកញ្ចាយខ្ជាយដៃពេក, ហៅថា សមជីវិតា ។

៤- ការសេពគប់នឹងកល្យាណមិត្រ គឺមិត្រដែលប្រព្រឹត្តត្រឹមត្រូវល្អដោយកាយ វាចា ចិត្ត, ហៅថាកល្យាណមិត្តតា ។

ទាំង ៤ យ៉ាងនេះ ហៅថាទិដ្ឋធម្មិកប្រយោជន៍ ជាប្រយោជន៍បច្ចុប្បន្ន ។

ឯសម្បរាយិកប្រយោជន៍ ជាប្រយោជន៍ដែលបានក្នុងកាលខាងមុខ ឬពេលមុខនោះ ក៏ចែកជា ៤ យ៉ាងដែរ គឺ :

១- ការបរិបូណ៌ដោយសទ្ធា គឺជំនឿចំពោះតែរឿងដែលគួរជឿ មានជឿថា ធ្វើអាក្រក់បានអាក្រក់ ធ្វើល្អបានល្អ និងការជឿគុណព្រះរតនត្រ័យជាដើម. យ៉ាងនេះហៅថាសទ្ធាសម្បទា ។

២- ការបរិបូណ៌ដោយការរក្សាកាយ វាចា ចិត្តឲ្យរាបសា មិនបើសម្ពន្ធ មិនបៀតបៀនសត្វដទៃ មិនឆក់ដណ្ដើមយកទ្រព្យសម្បត្តិអ្នកដទៃ ដែលគេមិនបានឲ្យដោយកាយ វាចា ចិត្ត មិនលួចគូនប្រពន្ធគេ មិននិយាយពាក្យកុហកបោកប្រាស់យកទ្រព្យគេ មិនសេពផឹកនូវទឹកស្រវឹង គឺមានចរិយាឫកពាល្អ គួរឲ្យអ្នកផងស្រឡាញ់ចូលចិត្ត ចង់គោរពបូជា យ៉ាងនេះ ហៅថា សីលសម្បទា ។

៣- ការបរិបូណ៌ដោយការករុណាអាសូរចំពោះអ្នកកំសត់ទុគ៌ត ហើយលះបង់ទ្រព្យសម្បត្តិចែកចាយឲ្យគាត់ទានតាមបាន ផង ក៏សមុខ និងការបូជាគុណមាតាបិតាជាដើម យ៉ាងនេះ ហៅថា ចាគសម្បទា ។

៦ - ការបរិបូណ៌ដោយការសិក្សារៀនសូត្រ ឬស្តាប់ពាក្យប្រៀនប្រដៅ ដើម្បីឲ្យកើតប្រាជ្ញាបរិពិចារណាស្គាល់គុណទោស ស្គាល់ខុសត្រូវ ស្គាល់ល្អអាក្រក់ ស្គាល់ហេតុផល ស្គាល់សេចក្តីវិនាសនិងចំរើនឬពិចារណាសង្កេតឲ្យឃើញថា ធម្មជាតិគ្រប់យ៉ាង ជារបស់មិនទៀងជាដើម, យ៉ាងនេះ ហៅថា បញ្ញាសម្បទា ។

សម្បទា ៦ យ៉ាងនេះ ហៅថា សម្បរាយិកប្រយោជន៍ជាប្រយោជន៍ដែលយើងត្រូវសន្សំទុកទៅបរលោក ឬក៏ទៅអនាគត ។

ប្រយោជន៍ទាំងពីរប្រការដូចបានពោលមកនេះ បើជនណាបានធ្វើបានសន្សំហើយ ជននោះឈ្មោះថាបានតាំងខ្លួនបានដោយប្រពៃរមែងវិលទៅកាន់សេចក្តីសុខ-ចំរើនតាមប្រាជ្ញា រាប់ថាជាមង្គលមួយយ៉ាងប្រសើរ ហៅថាបក្ខធម៌ទី ៣ ។

ទី ៤ - បុព្វេកតបុញ្ញតា ភាពជាអ្នកបានធ្វើសេចក្តីល្អទុកមកពីក្នុងកាលមុន ។ សេចក្តីថា ជនជាតិនីមួយៗ ដែលមានភោគសម្បត្តិ យសស័ក្តិ រូបពណ៌សណ្ឋានទ្រង់ទ្រាយល្អ ឬថ្កុំថ្កើងយ៉ាងណា ក៏សុទ្ធតែមកអំពីភ័ព្វសំណាងក្តី បានអប់រំសន្សំទុកមកពីក្នុងកាលមុន បើយើងធ្វើយ៉ាងណា ប្រព្រឹត្តយ៉ាងណា សិក្សាយ៉ាងណា ទោះបីតិចច្រើនក្តី ផលនឹងត្រឡប់ឲ្យផលវិញ ក៏រមែងទាញបន្តិចឲ្យតាមគំរូដើម មិនខុសហេតុខុសផលឡើយ ។ សូមទាញឧទាហរណ៍ឲ្យឃើញហេតុ

ផលក្នុងបច្ចុប្បន្ននេះថា ព្រះពុទ្ធជាម្ចាស់ក្តី ព្រះបច្ចេកពុទ្ធក្តី អគ្គសាវកក្តី ឬក៏ព្រះអរហន្តអង្គឯទៀតៗក្តី ដែលទ្រង់បានត្រាស់ជាព្រះពុទ្ធ ជាព្រះអរហន្ត លះកាត់កិលេសចូលទៅកាន់ព្រះនិព្វាន ហើយមានឈ្មោះថាជាអ្នកប្រាជ្ញយ៉ាងឯកក្នុងលោកនោះ ក៏អាស្រ័យមកអំពីបុណ្យកុសលដែលបានកសាងសន្សំទុកមកពីមុន ។ បើពុំនោះ ដូចយ៉ាងឥស្សរជនមានព្រះរាជា និងពួកអស់លោកឧកញ៉ាហ៊ានសព្វមុខមន្ត្រីធំតូច ប្រចាំតំណែងដែលទ្រង់បានឡើងទៅកាន់តំណែងជាន់ខ្ពស់ កណ្តាល ទាបបានយ៉ាងនេះ ក៏អាស្រ័យមកអំពីបានសាងការរៀនសូត្រពីខាងដើម តាមជាន់តាមថ្នាក់ ទើបអាចឡើងទៅកាន់តំណែងនោះៗបាន, មិនមែនបេះតែទៅកាន់ថ្នាក់នោះឯងៗបានឡើយ ។ អ្នកមានសម្បត្តិ អ្នកខ្សត់ខ្សោយសម្បត្តិក៏ដូចគ្នា, លុះតែខំប្រឹងរក ប្រឹងធ្វើទុកពីខាងដើម, ទើបសម្រេចផលប្រយោជន៍ទៅបាន ។ ដូចជាកិច្ចសង្គ្រោះគ្នាក្នុងបច្ចុប្បន្ននេះ គេជួយធ្វើយើង យើងត្រូវជួយធ្វើគេវិញ, គេឲ្យយើង យើងក៏ត្រូវឲ្យគេវិញ ។ សមដូចពុទ្ធភាសិតមួយពោលទុកថា បូជកោ លភតេ បូជំ វន្ទកោ បដិវន្ទនំ អ្នកបូជាគេ រមែងបានការបូជាមកវិញ អ្នកគំនាប់នាប់គេ រមែងបានទទួលការគំនាប់នាប់តបវិញ ។

សេចក្តីដែលបានសំដែងមកប៉ុណ្ណោះនេះដើម្បីនឹងតាញឲ្យឃើញថា សេចក្តីល្អដែលយើងបានធ្វើទុកមកពីកន្លងកាលមុនយ៉ាងណា ដល់មកខាងក្រោយ ក៏មែនឲ្យផលយ៉ាងនោះដែរ ។ ព្រោះហេតុនោះ បានជាព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងថា ភាពជាអ្នកធ្វើសេចក្តីល្អទុកមកពីកន្លងកាលមុននោះ ចាត់ថាជាចក្កមួយ រមែងវិលទៅកាន់សេចក្តីសុខ-ចំរើនក្នុងលោក រាប់ថាជាចក្កធម៌ទី ៤ ។

ហេតុនេះ សូមអស់លោក-អ្នកទាំងឡាយពួតដៃគ្នាជាកំឡាំងតាំងសេចក្តីព្យាយាមឲ្យរឹងប៉ឹងប្រឹងប្រែងប្រតិបត្តិតាមចក្កធម៌ទាំង ៤ យ៉ាងនេះ ទើបចក្កធម៌អាចវិលទៅកាន់សេចក្តីចំរើនឲ្យទាន់ពេលទាន់សម័យ គឺថាញ៉ាំងព្រះពុទ្ធសាសនានឹងប្រទេសជាតិ មាតុភូមិរបស់យើងឲ្យលឿនទៅមុខ កុំបណ្តោយតាមព្រេងសំណាងស្រុកទេសនោះឡើយ, បើយើងមិនប្រឹងទេ ព្រះពុទ្ធសាសនានឹងប្រទេសជាតិក៏នឹងសាបសូន្យទៅពុំខាន ។

សំដែងអំពីចក្កធម៌ ៤ យ៉ាង ចប់តែប៉ុណ្ណោះ ។

ទីបំផុតធម្មទេសនានេះ សូមផ្សាយកុសលបុញ្ញរាសីដល់អស់លោក-អ្នកទាំងឡាយទៅក្នុងកម្ពុជរដ្ឋទាំងមូល ឲ្យបានសេចក្តីសុខ-ចំរើនគ្រប់ប្រការ ។

ពុទ្ធានុភាវេន ឧបដ្ឋា ចេ ឧបទ្ទវា

ភេតា ចេវន្តរាយា ច វិនស្សន្តុ អសេសតោ

ដោយអានុភាពនៃព្រះរតនត្រ័យមានពុទ្ធរតនជាដើម បើឧបទ្រព និងភ័យ និងអន្តរាយទាំងឡាយ កើតមានហើយក៏សូមឲ្យវិនាសបាត់ទៅ កុំបីនៅមានសេសសល់ឡើយ (ដោយធម្មទេសនានេះ) ។

ចប់ បក្កដមិ

---